**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2016, 15:03
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ-កោសល្យ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦**

**ម៉ោង ១០:២៣នាទី**

**សវនាការលើកទី៣៥៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាធូវ ម៉ាកាធី *(Mr.Matthew Mccarthy)*
លោក ឯម ហ៊ុយ
កញ្ញា ជា ស៊ីវហ៉ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត
លោក ឌេល លីសាក់ *(Mr. Dale Lysak)*
លោក ត្រាវីស ហ្វារ *(Mr. Travis FARR)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ
លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

ឯកសារដើម

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ត្រាវីស ហ្វារ | អង់គ្លេស |
| សាក្សី 2-TCW-894 | ខ្មែរ |

សាធារណៈ

# ឧបសម្ព័ន្ធ

## ការសួរសំណួរទៅសាក្សី: 2-TCW-894

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ២៦
សួរដោយលោក ត្រាវីស ហ្វារ ផ្តើមពី ........ ទំព័រ ២៩
សួរបន្តដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៣០
សួរបន្តដោយលោក ត្រាវីស ហ្វារ ផ្តើមពី ........ ទំព័រ ៣០
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ៥៩

សាធារណៈ

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១៥:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះកំណត់កាលវិភាគធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-894 ដែលជាអសាធារណៈ។

ហើយក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះ កោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ មានរហស្សនាម 2-TCW-894 សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីម្សិលមិញនេះ។ សាក្សីមានមេធាវីប្រឹក្សាគឺលោក មឿន សុវណ្ណ។ សាក្សីនិងមេធាវីប្រឹក្សាមានវត្តមាននៅបន្ទប់រង់ចាំៗ ការកោះហៅពីអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:១៧:២៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបញ្ហាទី១ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ដោយថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បាន

យូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ បានកំណត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានការៈឈឺចង្កេះជាប្រចាំ អង្គុយយូរកាន់តែឈឺ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:១៨:៥៤]

ហើយមុននឹងបន្ត -- មុននឹងចាប់ផ្តើមស្តាប់សក្ខីកម្មដែលមានរហស្សនាម [2-TCW-894] អង្គជំនុំជម្រះសូមជម្រាបជូនភាគីថា អង្គជំនុំជម្រះបានទទួលនូវសំណើថ្មីៗពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីនៃភាពអសាធារណភាពនៃការស្តាប់សក្ខីកម្មសាក្សីចំនួនពីររូប។ បញ្ជាក់បន្ថែមជាលាយលក្ខណ៍អក្សរពីភាគីសហព្រះរាជអាជ្ញា ហើយរួមផ្សំនិងលិខិតឆ្លើយតបចុងក្រោយដែលអង្គជំនុំជម្រះបានទទួលពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង និងភាគីបានទទួលច្បាប់ចម្លងជូនជាព័ត៌មានពីសំណើសុំរបស់សហព្រះរាជអាជ្ញាដែលស្នើសុំឲ្យមានមូលហេតុដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់ឲ្យ ដើម្បីស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-936 និង2-TCW-894 ជាអសាធារណៈ។

សហព្រះរាជអាជ្ញាក៏បានស្នើសុំផងដែរថាឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីទាំងអស់ធ្វើសារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងបញ្ហានេះ។ អង្គជំនុំជម្រះសាលាដំបូងសម្រេចថាខ្លួននឹងធ្វើជូនអាសនៈ -- អនុស្ស-

រណៈរបស់សហចៅក្រមស៊ើបអង្កេតដែលអង្គជំនុំជម្រះទើបតែបានទទួលកាលពីម្សិលមិញជូនទៅភាគី ហើយអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យភាគីធ្វើសារណាផ្ទាល់មាត់។ ភាគីនឹងបានទទួលអនុស្សរណៈនេះក្នុងរយៈពេល១០នាទីខាងមុខនេះ។

អង្គជំនុំជម្រះនឹងផ្អាកសវនាការចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់ និងដប់ប្រាំនាទីដើម្បីឲ្យភាគមានឱកាសរៀបចំត្រៀមក្នុងការធ្វើសារណាផ្ទាល់មាត់។ ហើយបន្ថែមពីលើនេះ អង្គជំនុំជម្រះក៏នឹងគ្រោងស្តាប់នូវចម្លើយតបផ្ទាល់មាត់របស់ភាគីទៅនឹងសំណើសុំរបស់សហមេធាវីការពារក្តី ខៀវ សំផន ដែលបានដាក់សំណើតាមឯកសារ E372/1 បន្ទាប់ពីការស្តាប់នូវសារណាពាក់ព័ន្ធនឹងបញ្ហាអសាធារណភាព ឬសាធារណភាពនៃការស្តាប់សក្ខីកម្មសាក្សីទាំងពីររូបខាងលើនេះ។ សូមភាគីជ្រាប។ ដូច្នេះ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការនេះត្រឹមនេះសិន ដើម្បីទុកលទ្ធភាពជូនពេលវេលាគ្រប់គ្រាន់សមស្របជូនភាគីពិនិត្យបញ្ហានេះជាមុនសិន មុននឹងស្តាប់សារណារផ្ទាល់មាត់របស់ភាគី ហើយអាចបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកនេះឲ្យបានមុនម៉ោងដប់ និងដប់ប្រាំនាទី។

សម្រាកសិនចុះ!

*(សវនាការសម្រាកពីម៉ោង ០៩:២១ នាទី ដល់ម៉ោង ១០:២១ នាទី)*

[១០:២១:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ដូចដែលអង្គជំនុំជម្រះបានជម្រាបជូនភាគីកាលពីដើមដំបូងនៃសវនាការព្រឹកមិញនេះរួចហើយថា អង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់របស់ភាគីនៃសំណុំរឿង០០២/០២ ទៅលើអនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងការស្តាប់សក្ខីកម្មសាក្សីចំនួនពីររូប គឺសាក្សីដែលមានរហស្សនាម 2-TCW-894 និង 2-TCW-938 ជាអសាធារណៈ ហើយអនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវបានជូនទៅភាគីរួចហើយមុននេះ តាមរយៈអ៊ីម៉ែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង។ ដោយសារអនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាអនុស្សរណៈសម្ងាត់ ហេតុដូច្នេះ

អង្គជំនុំជម្រះ សម្រេចធ្វើសវនាការស្តាប់សារណាផ្ទាល់មាត់របស់ភាគីលើបញ្ហានេះជាអសាធារណៈ។

ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ផ្តាច់ កាត់ផ្តាច់នូវការផ្សព្វផ្សាយប្រព័ន្ធសំឡេង និងរូបភាព ដែលសម្រាប់ផ្សព្វផ្សាយចេញពីបន្ទប់សវនាការទៅសាលសវនាការធំសម្រាប់សាធារណជន ទៅបន្ទប់ផ្សព្វផ្សាយសម្រាប់អ្នកសារព័ត៌មាន និងទៅបុគ្គលិកនៃ អ.វ.ត.ក ផ្សេងទៀតដែលជាការផ្សាយតាមរយៈវីដេអូសម្រាប់ផ្ទៃក្នុង អ.វ.ត.ក លើកលែងតែអ្នកពាក់ព័ន្ធនៅក្នុងសាលាសវនាការនេះ។

ហើយជាដំបូងអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាដើម្បីឡើងធ្វើការបង្ហាញនូវសំណើសុំរបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះ។ សូមអញ្ជើញ!

*(សវនាការសាធារណៈផ្អាកនៅម៉ោង១០:២៣នាទី)*

*(សវនាការអសាធារណៈចាប់ពីម៉ោង១០:២៣នាទី)*

**លោក ខេល លីសាក់៖**

[redacted]

[redacted]

[១០:២៧:១០]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[១០:៣៩:២៣]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

[redacted]

*(មានបញ្ហាបច្ចេកទេស)*

*(សវនាការអសាធារណៈផ្អាកនៅម៉ោង១១:២១នាទី)*

*(បន្តសវនាការសាធារណៈពីម៉ោង១១:២១នាទី)*

[១១:២១:១៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវដំណើរការបានហើយ។ កាលពីម្សិលមិញក្រុមមេធាវីការពារក្តី ខៀវ សំផន បានដាក់សំណើមួយសុំឲ្យអង្គជំនុំជម្រះទទួលយកឯកសារមួយដែលមានលេខ E319/39.3.1 ធ្វើជាឯកសារភស្តុតាង ដើម្បីអាចសួរដេញដោលសាក្សីដែលមានរហស្សនាម 2-TCW-938។ ហើយអង្គជំនុំជម្រះជាដំបូងនេះ ផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសធ្វើការឆ្លើយតបទៅនឹង

សំណើរសុំរបស់ក្រុមសហមេធាវីការពារក្តីលោក ខៀវ សំផន ចំពោះការស្នើសុំដាក់បង្ហាញ -- ដាក់ស្នើសុំឱ្យទទួលយកឯកសារនេះ មកដាក់ជាឯកសារភស្តុតាងក្នុងការសួរដេញដោលសាក្សីរូបនេះ។

សូមអរញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំនឹងឆ្លើយតបដោយសង្ខេប យើងមិនមានការជំទាស់ទៅនឹងការទទួលស្គាល់ឯកសារនេះ ដាក់ជាភស្តុតាងនោះទេ បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បន្តទៅនេះ ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

យើងខ្ញុំក៏អត់មានការជំទាស់អ្វីដែរលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយបន្ទាប់ផ្តល់វេទិកាជូនទៅក្រុមសហមេធាវីការពារក្តីលោក នួន ជា។

**លោក វិុចទ័រ កូប៉េះ៖**

ខ្ញុំក៏មាន -- មិនមានអ្វីជំទាស់ដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងប្រហែលជាចុងក្រោយ សូមសហមេធាវីការពារក្តីលោក ខៀវ សំផន ទំនងមិនមានមតិយោបល់អ្វីទេតាមមើលទៅ ព្រោះភាគីទាំងអស់មិនជំទាស់តវ៉ាទៅនឹងសំណើសុំរបស់ក្រុមមេធាវី សហមេធាវីការពារក្តីលោក ខៀវ សំផន ទេ។ មានអ្វីបន្ថែមបន្ថយទៀតទេ លោកក្រុមមេធាវីការពារក្តី ខៀវ សំផន?

**កញ្ញា អង់តា ហ្គីសសេះ៖**

លោកប្រធាន គឺអត់មានអីទៀតទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះសូមអរគុណចំពោះរាល់មតិយោបល់របស់ភាគី ដែលបានលើកឡើងពិភាក្សាយ៉ាងផុសផុល លើបញ្ហាទី១ ហើយបញ្ហាទី២ គឺបានមិនមានមតិជំទាស់ទៅលើសំណើសុំទេ។

ដោយសារពេលវេលាវាសមស្របនឹងសម្រាកហើយ គឺ អង្គជំនុំជម្រះប្រកាសផ្អាកសវនាការនៅព្រឹកនេះត្រឹមនេះ ហើយសវនាការលើកទៅបន្តនៅវេលារសៀល ដែលចាប់ផ្តើមពីម៉ោងមួយនិងសាមសិបនាទី។ ហើយអង្គជំនុំជម្រះសូមជម្រាបថា អង្គជំនុំជម្រះនឹងយកចន្លោះពេលវេលានៃក្រោយអាហារថ្ងៃត្រង់នេះ នឹងពិភាក្សាសម្រេចលើបញ្ហានេះ និងចេញសេចក្តីសម្រេចផ្ទាល់មាត់មួយលើបញ្ហានេះឱ្យបានឆាប់បំផុតនៅមុនពេលស្តាប់ ដំណើរការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-894។

ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះឱ្យបានមុនម៉ោងមួយសាមសិបនាទីរសៀល។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៤ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:០០]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

តទៅនេះ ធ្វើសវនាការជាសាធារណៈ ដើម្បីផ្សព្វផ្សាយនូវសេចក្តីសម្រេចផ្ទាល់មាត់លើបញ្ហាចំនួនពីរដែលបានពិភាក្សាកាលពីព្រឹកមិញ។

ថ្ងៃនេះអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-894។ នៅសប្តាហ៍ក្រោយអង្គជំនុំជម្រះសាលាដំបូងគ្រោងនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-938។ កាលពីថ្ងៃម្សិលមិញ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចស្តាប់សក្ខីកម្មសាក្សីទាំងពីររូបនេះនៅក្នុងសវនាការជាអសាធារណៈទាំងស្រុង។

បន្ទាប់ពីសេចក្តីសម្រេចនេះ និងសំណើសុំជាច្រើនដងពីសំណាក់សហព្រះរាជអាជ្ញានោះ កាលពីព្រឹកមិញ អង្គជំនុំជម្រះបានស្តាប់សារណាផ្ទាល់មាត់របស់ភាគីនានា ទៅលើបញ្ហានេះ។

[១៣:៣៤:៥៦]

អង្គជំនុំជម្រះបានពិចារណាទៅលើសារណារបស់ភាគីនានា មិនមានអ្វីដែលកែប្រែសេចក្តីសម្រេចរបស់អង្គជំនុំជម្រះក្នុងការស្តាប់សក្ខីកម្មសាក្សីទាំងពីរក្នុងសវនាការជាអសាធារណៈនោះទេ។ ទោះបីជាអង្គជំនុំជម្រះមានបំណងធានាឲ្យសាធារណជនបន្តដឹងអំពីការជំនុំជម្រះលើសំណុំរឿង០០២/០២ ជាសាធារណៈក៏ដោយ ក៏អង្គជំនុំជម្រះត្រូវពិចារណាលើកត្តាផ្សេងៗជាច្រើនទៀត សំអាងហេតុពេញលេញចំពោះសេចក្តីសម្រេចនេះនឹងត្រូវផ្តល់ជូនជាលាយលក្ខណ៍អក្សរនៅពេលសមស្របខាងមុខ ហើយ អង្គជំនុំជម្រះនឹងព្យាយាមធ្វើឲ្យសាធារណជនបានដឹងអំពីសំអាងហេតុទាំងនេះ។

បន្ទាប់ពីសក្ខីកម្មសាក្សីទាំងពីរនៅក្នុងសវនាការជាអសាធារណៈបានចាប់សព្វគ្រប់ ដោយសហការជាមួយនឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងនឹងព្យាយាមផ្សព្វផ្សាយប្រតិចារឹកជាសាធារណៈនៃសក្ខីកម្មរបស់សាក្សីទាំងពីរនេះ ដោយត្រូវធ្វើការកោសលុបទៅតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ បន្ថែមពីលើនេះ អនុស្សរណៈ -- អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងសម្រេចអនុញ្ញាតតាមសំណើសុំរបស់សហមេធាវីការពារក្តី ខៀវ សំផន នូវឯកសារតាមសំណើសុំឯកសារ E373/1 ដែលស្នើសុំឲ្យទទួលយកជាឯកសារភស្តុតាងនូវឯកសារ E319/39.3.1។

[១៣:៣៦:៤០]

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះនឹងផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ដែលមានរហស្សនាម 2-TCW-894 ក្នុងសវនាការជាអសាធារណៈ ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ផ្តាច់ប្រព័ន្ធផ្សព្វផ្សាយសំឡេង និងរូបភាព ដែលសម្រាប់ផ្សព្វផ្សាយចេញពីបន្ទប់សវនាការទៅសាលសវនាការធំ សម្រាប់សាធារណជន ទៅបន្ទប់ផ្សព្វផ្សាយសម្រាប់អ្នកសារព័ត៌មាន និងទៅបុគ្គលិក អ.វ.ត.ក ផ្សេងទៀត តាមរយៈការផ្សាយតាមវីដេអូសម្រាប់ផ្ទៃក្នុង អ.វ.ត.ក លើកលែងអ្នកដែលពាក់ព័ន្ធនៅក្នុងសាលសវនាការនេះ។ ហើយពេលណារួច មន្ត្រីរដ្ឋបាលតុលាការប្រាប់មកខ្ញុំ ដើម្បីខ្ញុំបន្តកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់ទៀត។

*(សវនាការសាធារណៈផ្អាកនៅម៉ោង១៣:៣៧នាទី)*

*(បន្តសវនាការអសាធារណៈពីម៉ោង១៣:៣៧នាទី)*

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៨:០៨]

**ប្រធានអង្គជំនុំ៖**

បាទ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-894 និងមេធាវីប្រឹក្សាសាក្សីលោក មឿន សុវណ្ណ ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

អត់មានការបកប្រែភាសា? មានការបកប្រែទេ មានឮទេ អ្នកបកប្រែ?

បាទ អំមិញ យើងបង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី ដែលមានរហស្សនាម 2-TCW-894 និងមេធាវីប្រឹក្សាសាក្សី លោក មឿន សុវណ្ណ ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្ដីលោកស្រីសាក្សី តើលោកស្រីឈ្មោះអ្វី?

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** យូ វ៉ាន់។

**ស៖** លោកស្រី យូ វ៉ាន់ កើតនៅថ្ងៃខែឆ្នាំណា? លោកស្រីចាំទេ?

**ឆ៖** អត់បានចាំផង។

**ស៖** បាទ អរគុណ ហើយមិនអីទេ។ ចុះដល់ឆ្នាំនេះ លោកស្រីអាយុប៉ុន្មានហើយ?

**ឆ៖** ហា -- ៥៥។

**ស៖** អរគុណ ហើយលោកស្រីសព្វថ្ងៃរស់នៅទីកន្លែងណា?

**ឆ៖** ខ្ញុំនៅខេត្តកំពង់ចាម។

**ស៖** នៅភូមិអី ឃុំអី ស្រុកអី ដែរ?

**ឆ៖** នៅភូមិក្បាលហុងថ្មី ស្រុកចំការលើ ខេត្តកំពង់ចាម។

**ស៖** ហើយប្រកបមុខរបររកស៊ីធ្វើអីសព្វថ្ងៃនេះ?

**ឆ៖** ធ្វើស្រែ។

**ស៖** អរគុណ ហើយបង្កើតរបស់ -- ឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ឆ៖** គាត់ស្លាប់បាត់អស់ទៅហើយ។

**ស៖** យើងសួរឈ្មោះ មិនមែនសួរស្លាប់ ឬរស់ទេ។ គាត់ឈ្មោះអី? ហើយឪពុកបង្កើតរបស់លោកស្រីឈ្មោះអី? ម្ដាយបង្កើតរបស់លោកស្រី គាត់ឈ្មោះអី?

**ឆ៖** គាត់ តុប, យាយយ៉ាវ – ម្ដាយឈ្មោះ យ៉ាវ។

[១៣:៤២:៥១]

**ស៖** អរគុណ ហើយប្ដីរបស់លោកស្រីឈ្មោះអី? លោកស្រីមានគ្រួសារទេ?

**ឆ៖** ខ្ញុំមាន។ ប្ដីឈ្មោះ ខាត់ ប៊ុនឆៃ។

**ស៖** អរគុណ ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ឆ៖** មានប្រាំពីរនាក់។

**ស៖** អរគុណលោកស្រី យូ វ៉ាន់។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការ ថាតាមសមត្ថភាពដែលលោកស្រីអាចដឹង គឺលោកស្រីមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះទេ តើពិតមែនដែរទេ?

**ឆ៖** ពិតហើយ ព្រោះខ្ញុំមិនដែលស្គាល់។

**ស៖** តើលោកស្រីបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែក នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលនៅខាងកើតសាលសវនាការនេះរួចហើយឬនៅ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ?

**ឆ៖** ធ្វើរួចហើយម្សិលមិញ។

**ស៖** បាទអរគុណ។ ហើយជាតទៅនេះ អង្គជំនុំជម្រះប្រាប់អំពីសិទ្ធិ និងករណីយកិច្ច ក្នុងឋានៈលោកស្រីជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក យូ វ៉ាន់ ក្នុងឋានៈលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតប ឬក៏សុំឱ្យលោកស្រីរៀបរាប់បញ្ហាណាមួយដែលនាំឱ្យដាក់ពិរុទ្ធភាពលើកខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

[១៣:៤៥:០០]

អំពីករណីយកិច្ចលោកស្រី យូ វ៉ាន់ ក្នុងកិច្ចដំណើរការសវនាការនេះ លោកស្រីត្រូវឆ្លើយតបទៅនឹងរាល់សំណួរដែលភាគី ឬចៅក្រមសួរចំពោះលោកស្រី លើកលែងតែសំណួរណា ឬក៏ការតម្រូវឱ្យលោកស្រីរៀបរាប់ឯណាដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯងដូចយើងប្រាប់អំពីសិទ្ធិរួចហើយ។ ហើយ

អំពីករណីយកិច្ចមួយទៀតគឺថា លោកស្រីត្រូវតែឆ្លើយឲ្យតែការណ៍ណាដែលពិតដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់ នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។ ហើយលោកស្រី យូ វ៉ាន់ តើលោកស្រីចេះអក្សរដែរទេ?

**ឆ៖** ខ្ញុំរៀនបានបន្តិចបន្តួចថ្នាក់ទី៩ ពីដើម។

**ស៖** បាទ អរគុណ។ ហើយរយៈពេលកន្លងមកនេះ តើលោកស្រីធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយបើសិនបើធ្លាប់បានផ្តល់សក្ខីកម្មនោះ តើធ្វើប៉ុន្មានដង ធ្វើនៅកន្លែងណា?

**ឆ៖** ធ្វើម្តងនៅ គាត់តាមទៅដល់ផ្ទះ។ ធ្វើពីរដង ធ្វើនៅកន្លែងសាក្សី។ ធ្វើបានពីរដង។

**ស៖** បាទ អរគុណ។ ហើយមុនចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកស្រីបានពិនិត្យមើល ឬបានអាន ឬស្តាប់ការអាននូវកំណត់ហេតុដែលលោកស្រីបានផ្តល់សក្ខីកម្មកាលពីពេលមុនដើម្បីរំឭកការចងចាំរបស់លោកស្រីដែរឬទេ?

**ឆ៖** ខ្ញុំមើល ប៉ុន្តែខ្ញុំមិនសូវចាំទេ។

**ស៖** បាទ អរគុណ ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំ តើលោកស្រីអាចបញ្ជាក់បានដែរទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកស្រីបានអាន ដើម្បីរំឭកការចងចាំនោះវាពិតជាត្រឹមត្រូវ វាសមស្រប ហើយវាស៊ីចង្វាក់គ្នាទៅនឹងអ្វីដែលជាលោកស្រីបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពីរលើកមុន ដែលលោកស្រីថា អះអាងថា ពីរ ចំនួនពីរលើកនោះដែរឬទេ?

**ឆ៖** ខ្ញុំសមស្រប ហើយនិងពេញចិត្តទៀត។

[១៣:៤៧:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន ៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការតាំងសំណួរដេញដោល

ចំពោះសាក្សីរូបនេះ។ សូមអញ្ជើញបាទ!

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។ ជម្រាបសួរលោកស្រី យូ វ៉ាន់។ ខ្ញុំឈ្មោះ ត្រាវីស ហ្វារ ជាមេធាវីមកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំសួរសំណួរមួយ ចំនួនទៅកាន់លោកស្រីនៅរសៀលនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** មុនដំបូង ខ្ញុំសូមត្រឡប់ទៅសួរអំពីអំឡុងពេលឆ្នាំ១៩៧៥ នៅពេលដែលលោកស្រីនៅភូមិភាគនិរតីមុននឹងមកភូមិភាគកណ្តាល។ នៅពេលដែលលោកស្រីនៅឯភូមិភាគនិរតី តើលោកស្រីមានតួនាទីអ្វីដែរ?

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** ខ្ញុំ តួនាទីជានីរសាររបស់ ប្រាក់ យុត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[redacted]

[redacted]

[១៣:៥០:៥៧]

[redacted]

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញបន្តទៀត សហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកស្រីសាក្សី ខ្ញុំសួរលោកស្រីពេលដែលលោកស្រីនៅខេត្តកំពត នៅក្នុងខេត្តកំពត ពេលនោះ តើលោកស្រីមានតួនាទីអ្វីដែរ?

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** ខ្ញុំអត់ទាន់មានភរិយាផង។

[១៣:៥២:៣៨]

[redacted]

លោកស្រីនៅចាំទេថាពេលនៅក្នុងខេត្តកំពតក្នុងឆ្នាំ១៩៧៥នោះ គឺលោកស្រីនៅក្នុងកងកាត់ដេរ?

**ឆ៖** ខ្ញុំនៅកងកាត់ដេរមែន។

**ស៖** តើកំណត់ហេតុស្ដាប់ចម្លើយ ចម្លើយលោកស្រីនេះ គឺត្រឹមត្រូវដែរទេ ដែលខ្ញុំអានអម្បាញ់មិញថា ពេលនោះមេរបស់លោកស្រី គឺឈ្មោះ ប្រាក់ យុត?

**ឆ៖** ចាស។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេ ប្រាក់ យុត ជាអ្នកណា?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

មិនមែនជាការជំទាស់ទេ គ្រាន់តែជាការកត់សម្គាល់សម្រាប់ប្រតិចារឹក គឺថាគាត់នៅកងកាត់ដេរខោអាវ កងទ័ព។ វា ជាចំណុចតូចទេ ប៉ុន្តែជាការកត់សម្គាល់។

[១៣:៥៤:៥៣]

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** ពាក្យអង់គ្លេសអានទៅស្រដៀងគ្នា *ស៊ូវីង សូវីង* ហ្នឹង។ តើលោកស្រីអាចជម្រាបជូនតុលាការបានទេ ប្រាក់ យុត ជាអ្នកណា?

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** ប្រាក់ យុត គាត់មុនដំបូង ខ្ញុំជួបដំបូងគាត់បានធ្វើនៅអនុខេត្តកំពត បន្ទាប់មកគេបញ្ជូនគាត់ពីភូមិភាគនិរតីមកនៅកំពង់ចាម។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** ហើយនៅក្នុងតាមរយៈការបកប្រែនេះ លោកស្រីតាមជាភាសាអង់គ្លេសប្រើ *ហ៊ី* ហ្នឹងគឺថាជាប្រុសទេ។ សួរឲ្យច្បាស់មក ប្រាក់ យុត ស្រី ឬក៏ប្រុស?

**ឆ៖** ប្រាក់ យុត (ស្រី)។

**ស៖** សូមអរគុណ។ ក្នុងពេលលោកស្រីនៅខេត្តកំពត តើអ្នកណាជាមេភូមិភាគនិរតីពេលនោះ?

**ឆ៖** តាម៉ុក។

**ស៖** ហើយនៅពេលដែលលោកស្រីនៅឯភូមិភាគនិរតីជា -- ដែល ប្រាក់ យុត ជាប្រធានរបស់លោកស្រីហ្នឹង តើនៅពេលនុ៎ង លោកស្រីដឹងថា ប្រាក់ យុត ហើយនិង តាម៉ុក ស្គាល់គ្នាទេ?

**ឆ៖** ដឹង គាត់ស្គាល់គ្នាតាមខ្សែរយៈភូមិភាគនិរតី។

[១៣:៥៦:៤៣]

**ស៖** ហើយតើលោកស្រីអាចជម្រាបជូនតុលាការបន្ថែមបានទេ រវាងអ្នកទាំងពីរ ។ហ្នឹងធ្វើការជាមួយគ្នាអត់? ជិតស្និទ្ធនឹងគ្នាទេ យ៉ាងណាដែរ សូមលោកស្រីរៀបរាប់កន្លែងនេះ ឲ្យលម្អិតបន្តិចបានទេ?

**ឆ៖** ពីរនាក់ហ្នឹង មួយប្រធាន មួយជា ដូចជា ឧទាហរណ៍ សមាជិកអ៊ីចឹង គាត់ជិតស្និទ្ធដូចជាឪពុកនឹងកូនអ៊ីចឹង ធ្វើការរាល់ថ្ងៃ តាមច្បាប់របស់រដ្ឋ។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចូលទៅនិយាយពីពេលវេលាដែលលោកស្រីចាកចេញពីភូមិភាគនិរតីមកភូមិភាគកណ្ដាល។ តើលោកស្រីចាំអ្វីខ្លះដែរ គិតពីពេលដែលលោកស្រីចាកចេញពីភូមិភាគនិរតីមកដល់ភូមិភាគកណ្ដាល ចាំព្រឹត្តិការណ៍អ្វីខ្លះដែរចន្លោះពេលនោះ?

**ឆ៖** ចាស ខ្ញុំចេញពីភូមិភាគនិរតី ខ្ញុំអត់បាននៅខេត្តកណ្ដាលទេ។ ខ្ញុំនៅខេត្តកំពង់ចាម តំបន់៤១។

**ស៖** តើហេតុអ្វីបានជាលោកស្រីចាកចេញពីខេត្តកំពត ទៅខេត្តកំពង់ចាម នៅក្នុងតំបន់៤១នោះ អ្នកណាជាអ្នកដែលបានប្រាប់លោកស្រីឲ្យចាកចេញពីខេត្តកំពត ហើយលោកស្រីចាកចេញមកជាមួយអ្នកណា? ហើយមានអ្វីកើតឡើងជាបន្តបន្ទាប់មុនពេលទៅដល់ទីនោះ?

**ឆ៖** គឺរឿងហ្នឹងដឹកនាំរបស់ តាម៉ុក និង ប្រាក់ យុត និង តាចាប ហើយខ្ញុំចេញមកជួយធ្វើជានីរសារនៅខេត្តកំពង់ចាម។

**ស៖** ពេលលោកស្រីចេញពីកំពត ទៅកំពង់ចាម អ្នកណារួមដំណើរមកជាមួយលោកស្រីខ្លះដែរ?

[១៣:៥៩:០៥]

**ឆ៖** គឺតាម៉ុក និង ប្រាក់ យុត មកជាមួយ។ មកគ្នាដោយច្រើន ខ្ញុំរាប់មិនអស់ទេ ព្រោះខ្ញុំមិនសូវដឹងដែរ អង្កាល់ហ្នឹង។

[redacted]

**សះ** លោកស្រីទើបតែបានឆ្លើយថា តាម៉ុក និង ប្រាក់ យុត ជាអ្នកប្រាប់លោកស្រីឲ្យទៅទីនោះ តើលោកស្រីអាចជម្រាបតុលាការបានទេ អ្នកណាជាអ្នកប្រាប់លោកស្រីដោយផ្ទាល់មាត់ ប្រាក់ យុត ឬក៏តាម៉ុក ដែលប្រាប់លោកស្រីដោយផ្ទាល់មាត់ ឲ្យចាកចេញទៅភូមិភាគកណ្តាលហ្នឹង?

**ឆ៖** គឺប្រាក់ យុត។

**សះ** ដោយសារថាលោកស្រីបានទទួលការបញ្ជាពី ប្រាក់ យុត តើលោកស្រីដឹងថា តាម៉ុក ក៏ជាអ្នកចូលរួមក្នុងការធ្វើសេចក្តីសម្រេចបញ្ជូនលោកស្រីទៅហ្នឹងដែរឬក៏អត់ទេ?

[១៤:០០:៥៣]

**ឆ៖** គឺ ប្រាក់ យុត បញ្ជា មកពីអ្នកបកប្រែ បានគាត់អត់ប៉ានប្រាប់ខ្ញុំឲ្យមក។ តាម៉ុក ហ្នឹងគាត់ប្រធាន ប្រាក់ យុត ទៀត។

**សះ** តើលោកស្រីដឹងទេហេតុអ្វីបានជាគេធ្វើសេចក្តីសម្រេចបញ្ជូនមនុស្ស [redacted] ពីភូមិភាគនិរតីទៅភូមិភាគកណ្តាលហ្នឹង?

**ឆ៖** មកដំបូងខ្ញុំអត់ដឹងអីដែរ បានដល់ ចែកមកដល់ខេត្តកំពង់ចាមទៅ ណាគ្នាចែកតាមខេត្តទៅ ក៏នាំគ្នាចែកតាមស្រុកទៀតហើយបានចែកគ្នាអ៊ីចឹងទៅ ក៏ខ្ញុំក៏បាននៅជាគាត់រហូតទើសឆ្នាំដាច់យួនហ្នឹងតែម្តង។

**សះ** ឥឡូវ យើងផ្តោតតែពីការធ្វើដំណើររបស់លោកស្រីពីកំពត ទៅខេត្តកំពង់ចាម។ តើលោកស្រីនៅចាំថាពេលធ្វើដំណើរហ្នឹង មានៗដេកផ្លូវនៅត្រង់កន្លែងណាមួយដែរ?

**ធ៖** មានដេកនៅភ្នំពេញ ប៉ុន្តែខ្ញុំអត់ចាំ។ នៅសាលាសកលវិទ្យាល័យ ប៉ុនខ្ញុំអត់ចាំ ភ្លេចទៅ។ មានដេកមួយយប់។

**ស៖** ក្នុងពេលលោកស្រីស្នាក់នៅក្នុងសាលារៀនហ្នឹង បរិវេណសកលវិទ្យាល័យហ្នឹង តើមានអ្វីកើតឡើងទៅទៀត?

**ធ៖** អត់មានអីគួរឱ្យអស្ចារ្យទេ ខ្ញុំដេកព្រលឹមឡើងឃើញលោក ខៀវ សំផន ទៅសម្ភោធ។ ខ្ញុំនៅលើឡាន។ គាត់អត់ចុះទេ ឃើញចុះ -- ខ្ញុំឈរៗរាដៃខាងអ៊ីចេះ គ្រាន់តែឃើញថា ខៀវ សំផន នាំគ្នារាដៃអ៊ីចឹងទៅ គាត់អត់មានចុះទទួលយើងទេ ប៉ុណ្ណឹងគាត់ទៅបាត់ទៅ។

[១៤:០៣:២៤]

[redacted]

**ស៖** លោកស្រីដឹងថា អ្នកទាំង១ប៉ុន្មាននាក់អម្បាញ់មិញនេះ ជួបជាមួយអ្នកណាដែរ?

**ធ៖** ខ្ញុំដឹងស្មានថា ទៅជួបនឹង ខៀវ សំផន តែម្តង។

**ស៖** ហេតុអ្វីបានជាលោកស្រីជឿថាអ្នកទាំងនោះ ទៅជួបជាមួយនឹង ខៀវ សំផន?

**ធ៖** ព្រោះគាត់ទៅប្រជុំហើយ ដល់ព្រឹកឡើង គាត់ប្រាប់ខ្ញុំថា៖ "ព្រឹកឡើង ខៀវ សំផន មកសម្ភោធ" បានខ្ញុំច្បាស់ខ្លួនខ្ញុំថា គាត់ទៅប្រជុំមែន។

**ស៖** តើលោកស្រីមានបានដឹងថាពេលដែលពួកគេទៅប្រជុំហ្នឹង តើគេនិយាយគ្នាអំពីអ្វីដែរ មានកម្មវត្ថុអ្វី ប្រធានអី ដែលគេត្រូវនិយាយគ្នាដែរទេ?

**ធ៖** ខ្ញុំអត់បានដឹងដែរ ព្រោះគាត់ថាទៅប្រជុំនៅឯវាំង។

**ស៖** សូមអរគុណ ឥឡូវនេះខ្ញុំសុំសួរអំពីពេលវេលា។ ក្រោយពេលលោកស្រីទៅដល់ខេត្តកំពង់ចាម តើក្រុមមនុស្ស [redacted] ដែលលោកស្រីទៅជាមួយនេះធ្វើអ្វីដែរ ក្រោយពេលទៅដល់ខេត្តកំពង់ចាមហើយនោះ?

**ធ៖** ខ្ញុំទៅដល់ខេត្តកំពង់ចាម ខ្ញុំធ្វើនីរសារបានមួយឆ្នាំ កន្លងផុតបានពីរឆ្នាំ ខ្ញុំចេញ គាត់ចាត់តាំងឱ្យខ្ញុំចេញធ្វើនៅកងចល័ត បញ្ជាការកងចល័ត ហើយបានកន្លះឆ្នាំ គាត់បញ្ជាខ្ញុំឱ្យធ្វើជាអនុឃុំ។ ដល់តែខ្ញុំធ្វើបានអនុឃុំ បានប៉ុន្មានខែ ក៏យួនចូលមកទៅ។ ខ្ញុំអស់ត្រឹមហ្នឹង។

[១៤:០៦:២១]

**ស៖** លោកស្រីបានឆ្លើយថា លោកស្រីបានប្រាប់ពីអ្វីលោកស្រីបានធ្វើនៅទីនោះ ក្រោយពេលទៅដល់ខេត្តកំពង់ចាម។ ចុះមនុស្ស[redacted]ផ្សេងទៀតនោះ គេធ្វើអ្វីដែរក្រោយពេលទៅដល់កំពង់ចាម?

**ឆ៖** គេចែកទៅធ្វើមេឃុំខ្លះ អនុឃុំខ្លះ ក៏នៅដេរខ្លះ។ មនុស្សហ្នឹងមិនជាច្រើនប៉ុន្មានទេ នៅកំពង់សៀម ប្រហែលជា៤០នាក់ទេ មកពីនិរតី។

**ស៖** ដូច្នេះលោកស្រីទើបតែនិយាយថា គេចាត់តាំងឲ្យពួកគេកាន់តំណែងជាមេឃុំ អនុឃុំ តើលោកស្រីដឹងដែរឬទេ មនុស្សផ្សេងទៀតដែលកាន់តំណែងនៅទីនោះ ពីមុនជាកម្មាភិបាលមូលដ្ឋាន ដែលធ្វើការនៅទីនោះស្រាប់ ពេលដែលពួកនិរតីទៅដល់ តើអ្នកចាស់នោះយ៉ាងម៉េចដែរ?

**ឆ៖** អ្នកចាស់ ខ្ញុំមិនបានដឹងដែរ ព្រោះឃើញតែវិនាសហិនហោច បាត់ម្តងមួយៗ ខ្ញុំក៏អត់ដឹងរឿងរបស់គេដែរ។

**ស៖** នៅពេលដែលលោកស្រីថា បាត់ម្តងមួយៗ សូមលោកស្រីបញ្ជាក់ជូនតុលាការឲ្យច្បាស់ជាងនេះបន្តិច ថាតើជោគវាសនា ឬក៏ពួកគាត់មានរឿងអ្វីទេ បានជាបាត់ ហើយបាត់យ៉ាងម៉េច បាទ?

**ឆ៖** ខ្ញុំក៏មិនបានដឹងរឿងហ្នឹងដល់ធំដុំដែរ ព្រោះជំនាន់ហ្នឹង ព្រោះខ្ញុំខ្លាចគ្រោះថ្នាក់ខ្លួនឯង។ ដឹងតែបាត់ៗ គេយកទៅលើ មិនដឹងយកទៅលើឯណាផង។

[១៤:០៨:៣០]

**ស៖** លោកទើបតែប្រាប់តុលាការថា លោកស្រីភ័យពីអាយុរបស់ខ្លួនឯងដែរ។ តើមានន័យដូចម្តេច ភ័យខ្លាចខ្លួនឯងដែរហ្នឹង?

**ឆ៖** ខ្ញុំមានន័យថា ព្រោះខ្ញុំធ្វើការបម្រើ ប្រាក់ យុត នេះ ខ្ញុំអស់ម្តាយរួចទៅហើយ បានខ្ញុំបារម្ភខ្លួនឯង ទុកឲ្យអាយុវែង។

**ស៖** ហេតុអ្វីបានជាលោកស្រីគិតថា អាចនឹងប៉ះពាល់ ឬក៏អាចនឹងមានបញ្ហាលើជីវិតរបស់ខ្លួនឯង?

**ឆ៖** គេគិតថា ខ្ញុំហ្នឹងកូនអ្នកមាន ក៏មិនអាយុវែងប៉ុន្មានដែរ។ បាន ខ្ញុំមិនហ៊ានប្រថុយប្រថានក្តាប់រឿងអស់ហ្នឹង។

**ស៖** បាទ ខ្ញុំឥឡូវនេះ សូមចូលទៅដល់សំណួរមួយចំនួនអំពីរចនាសម្ព័ន្ធ ហើយនិងថ្នាក់ដឹកនាំនៃតំបន់៤១ នៅពេលដែលលោកស្រីនៅទីនេះ។ ដើម្បីចាប់ផ្តើមសូមលោកស្រីជម្រាបតុលាការមើល តើ

អ្នកណាជាប្រធានភូមិភាគកណ្ដាល នៅពេលដែលលោកស្រីទៅដល់កំពង់ចាម កាលណោះ?

**ឆ៖** គឺ តាម៉ុក។

**ស៖** ហើយថាតើមានតំបន់ប៉ុន្មាននៅក្នុងភូមិភាគកណ្ដាល? តើលោកស្រីនៅចាំទេ មានតំបន់លេខទីប៉ុន្មានដល់លេខប៉ុន្មាន?

**ឆ៖** ខ្ញុំដឹងតែពីរតំបន់ទេ ព្រោះតំបន់៤១ និង តំបន់៤២។

**ស៖** បាទ ដូច្នេះយើងផ្ដោតទៅលើតំបន់៤១។ តើអ្នកណាជាលេខាតំបន់៤១?

**ឆ៖** គឺ តាអាន។

**ស៖** តើលោកស្រីដឹងដែរឬទេថា តាអាន គាត់រស់នៅកន្លែងណា? ថាមន្ទីរដែលគាត់ធ្វើការនោះនៅកន្លែងណា នៅពេលដែលលោកស្រីនៅតំបន់៤១ កាលណោះ?

**ឆ៖** គាត់នៅមន្ទីរស្រុកព្រៃទទឹង។

[១៤:១១:១២]

**ស៖** តាមអ្វីដែលលោកស្រីដឹងថា តើកន្លែងដែលគាត់រស់នៅ ហើយនិងកន្លែងដែលគាត់ធ្វើការបានន័យថាមន្ទីរគាត់ធ្វើការនៅកន្លែងតែមួយ ឬក៏វាខុសគ្នា?

**ឆ៖** នៅកន្លែងតែមួយ ព្រោះស្រុកព្រៃទទឹង គេធ្វើកន្លែងតំបន់ផង កន្លែងស្រុកផង។

[redacted]

[redacted]

**ស៖** សូមអរគុណលោកស្រីសាក្សីចំពោះការបំភ្លឺ។ នៅក្នុងតំបន់៤១ តើលោកស្រីដឹងថាមានប៉ុន្មានស្រុកនៅក្នុងតំបន់៤១ នេះ?

**ឆ៖** ខ្ញុំដឹងតែបីស្រុកទេ ស្រុកកំពង់សៀម ស្រុកព្រៃឈរ ស្រុកព្រៃទទឹង។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** បាទ អ៊ីចឹងកាលណោះលោកស្រីនៅក្នុងស្រុកមួយណាក្នុងចំណោមស្រុកទាំងបីនេះ?

**ឆ៖** ក្នុងស្រុកកំពង់សៀម។

**ស៖** តើស្រុកកំពង់សៀមហ្នឹងគឺចៅហ្វាយស្រុក ឬក៏លេខាស្រុកឈ្មោះអ្វី?

[១៤:១៣:១២]

**ឆ៖** ឈ្មោះ ប្រាក់ យុត។

**ស៖** តើលោកស្រីនៅចាំដែរឬទេ គឺអ្នកណាជាប្រធានយោធាស្រុកកំពង់សៀម ឬក៏លេខាខាងយោធានៅស្រុកកំពង់សៀមនោះ?

**ឆ៖** ប្រធានយោធាគឺឈ្មោះ ផុន ប្រធានយោធាស្រុក, អនុឈ្មោះ ផែន ប៉ុន្តែស្លាប់បាត់អស់ហើយ។

**ស៖** ហើយនិយាយជាទូទៅ តើៗមុខងារ ហើយនិងការទទួលខុសត្រូវរបស់យោធាស្រុកកំពង់សៀមនោះមានអ្វីខ្លះ? គេធ្វើអ្វីខ្លះ?

**ឆ៖** គេដឹកនាំកងទ័ពស្រុក។

**ស៖** តើ -- ចុះយោធាស្រុកគេធ្វើអ្វី? គេធ្វើការងារសំខាន់របស់គេអ្វីខ្លះនៅក្នុងស្រុកហ្នឹង?

**ឆ៖** គេអត់បានធ្វើអ្វីផង គេដឹកនាំទាហានអ៊ីចឹងទៅ ថ្ងៃឡើងដាំបន្លែហូបទៅ ក៏យប់ឡើងគេដើរយាមល្បាតប្រជាជន។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

**ស៖** តាមអ្វីដែលលោកស្រីចាំ តើយោធាស្រុកបានចូលរួមនៅក្នុងការចាប់ខ្លួនមនុស្សដែរឬទេ?

**ឆ៖** បាន។ ខ្ញុំដឹងមួយចំណែក គ្រាន់ថាខ្ញុំមិនដឹងមួយចំណែក។ គ្រាន់ថា គ្រាន់តែដឹង ប៉ុនខ្ញុំមិនប៊ានៗនិយាយ។ មិនដឹងគេយកទៅណា មិនដឹងគេមកណា ខ្ញុំអត់ដឹង។

**ស៖** សូមលោកស្រីប្រាប់ខ្ញុំថា តើលោកស្រីដឹងដោយរបៀបណាថា យោធាស្រុកហ្នឹងចូលក្នុងការចាប់ខ្លួនមនុស្ស?

**ឆ៖** ព្រោះខ្ញុំរត់សំបុត្រនីរសារ ព្រោះ ប្រាក់ យុត ហ្នឹងគាត់និយាយប្រាប់ ថ្ងៃនេះគេចាប់អ្នកនេះ ថ្ងៃនោះគេចាប់នោះ។

[១៤:១៦:០៥]

**ស៖** តើលោកស្រីដឹងដែរឬទេថា តើយោធាស្រុកនោះ គេមានមន្ទីររបស់គេទេ? បើមាន ករណីដែលមានមន្ទីរហ្នឹង មន្ទីរគេឈ្មោះអ្វី?

**ឆ៖** អត់មានមន្ទីរគេសំខាន់ទេ នៅតាមផ្ទះក្បែរវត្តអង្គញដី។

**ស៖** ថាតើផ្ទះនោះនៅកន្លែងណា បើប្រៀបធៀបទៅនឹងមន្ទីរស្រុកដែល ប្រាក់ យុត គាត់ធ្វើការនោះ?

**ឆ៖** មន្ទីរទាហានហ្នឹង វានៅជាប់នឹងមន្ទីរស្រុកដែរ មួយគ្រាន់តែ -- គ្រាន់ថាឆ្លងផ្លូវតិចតួច ផ្ទះ

តូចទេ។ មន្ទីរទាហានហ្នឹង គាត់អត់បានធ្វើទេ នៅរួមគ្នា គ្រាន់តែបែកផ្ទះ។

**ស៖** តើលោកស្រីនៅចាំដែរឬទេ អ្នកណាជាលេខា ឬក៏ប្រធានមន្ទីរសន្តិសុខស្រុកកំពង់សៀម?

**ឆ៖** ប្រធានតាមស្រុកហ្នឹងឈ្មោះ នី។

**ស៖** តើ នី ហ្នឹងមានស្រុកកំណើតនៅឯណា?

**ឆ៖** នៅឯតាកែវ។

**ស៖** តើលោកស្រីដឹង -- លោកស្រីស្គាល់គាត់មុនពេលដែលគាត់ទៅដល់តំបន់៤១ ដែលលោកស្រីធ្វើការ កាលពីនៅភូមិភាគនិរតី លោកស្រីស្គាល់គាត់ទេ?

**ឆ៖** ខ្ញុំបានស្គាល់ ព្រោះបានធ្វើដំណើរទៅជាមួយគ្នា គេចាត់តាំងគាត់ឲ្យធ្វើប្រធានសន្តិសុខ។

**ស៖** សូមលោកប្រាប់ -- លោកស្រីប្រាប់ខ្ញុំថា តើមុខងារ ឬក៏ភារកិច្ចរបស់កងមន្ទីរសន្តិសុខហ្នឹង ដែលធ្វើការក្រោមបញ្ជារបស់ នី នោះ អ្នកទាំងនោះគេធ្វើការអី ជាភារកិច្ចប្រចាំថ្ងៃរបស់គេ?

**ឆ៖** នី ហ្នឹងយាមខាងសន្តិសុខ យាមអ្នកទោស នៅក្រោមបញ្ជារបស់ ផុន និង ផែន ទេ នីហ្នឹង។

[១៤:១៨:៤៩]

**ស៖** តើមន្ទីរសន្តិ -- បាទ សមាជិកមន្ទីរសន្តិសុខស្រុកហ្នឹង បានពាក់ព័ន្ធក្នុងការចាប់ខ្លួនមនុស្សដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះគេរកស៊ីយប់។ ខ្ញុំនៅតែថ្ងៃ។

**ស៖** តើលោកស្រីដឹងដែរឬទេ ថាពួកសន្តិសុខហ្នឹង គេមានមន្ទីររបស់គេដែរឬទេ?

**ឆ៖** មាន នៅភូមិរការបេង។

**ស៖** តើលោកស្រីដឹងដែរឬទេថា នៅកន្លែងណាមួយមានមន្ទីរឃុំខ្លួននៅក្នុងស្រុកនុំងទេ ឬក៏នៅជិតមន្ទីរសន្តិសុខដែរឬទេ?

**ឆ៖** នៅនឹងភូមិចំការបេងហ្នឹងតែហ្នង។ មន្ទីរសន្តិសុខហ្នឹង គេឃុំតែហ្នឹង អីហ្នឹង។

**ស៖** តើលោកស្រីដឹងដែរឬទេ ថាតើក្រុមមនុស្សប្រភេទណាដែលគេយកទៅឃុំខ្លួននៅកន្លែងនោះ ហើយតើដឹងទេ មូលហេតុអីបានជាគេយកអ្នកនោះ ទៅឃុំខ្លួននៅកន្លែងនោះ?

**ឆ៖** ខ្ញុំដឹងតែមនុស្សជាប់នឹង ជាទាហានចាស់ និងពួកចាម និងពួកយួន ប៉ុន្តែចំនួនខ្ញុំអត់បានដឹងដែរ។ គេយកមកឃុំហ្នឹងទៅក៏បាត់ទៅ – គេយកមកឃុំហ្នឹងក៏បាត់ទៅ។

**សៈ** នៅពេលដែលលោកស្រីនិយាយថា "បាត់ទៅៗ" តើមានន័យដូចម្តេច?

**ឆៈ** ខ្ញុំមិនដឹងដែរ ព្រោះដឹងថា មនុស្សហ្នឹងបាត់ខ្លួន ខ្ញុំមិនហ៊ាននិយាយ ព្រោះខ្ញុំខ្លាចគ្រោះថ្នាក់ខ្លួនឯង។

**សៈ** តើលោកស្រីដឹងដែរឬទេថា ប្រាក់ យុត ហ្នឹងគឺថា គាត់ត្រួតលើ ឬក្តោបក្តាប់លើមន្ទីរសន្តិសុខស្រុក ឬក៏មន្ទីរយោធាស្រុកដែរឬទេ?

**ឆៈ** គាត់ក្តាប់ទាំងអស់ ទាំងពួកកងទ័ព ទាំងពួកនគរបាល [redacted]

**សៈ** ឥឡូវនេះ ផ្តោតអារម្មណ៍ទៅលើឃុំនៅក្នុងស្រុកកំពង់សៀមវិញ សូមលោកស្រីជម្រាបតុលាការករណីដែលលោកស្រីចាំ តើមានឃុំប៉ុន្មាននៅក្នុងស្រុកកំពង់សៀម ហើយប្រាប់ឈ្មោះ ឃុំទាំងនោះផង?

**ឆៈ** ខ្ញុំដឹងមានឃុំស្រក ឃុំល្អាក់ ឃុំរអាង ឃុំរំលេច ឃុំទ្រាន រកា និងកោះទន្ទឹម កោះមិត្ត។ ខ្ញុំដឹងតែប៉ុណ្ណឹងទេ។

[១៤:២២:២៣]

**សៈ** អរគុណលោកស្រី បាទ។ លោកស្រីបញ្ជាក់ខាងដើមថា លោកស្រីធ្វើជានីរសារឲ្យ ប្រាក់ យុត នៅពេលមួយនោះ។ សូមលោកស្រីបញ្ជាក់ប្រាប់តុលាការថា ភារកិច្ចអ្វីខ្លះកាលធ្វើជានីរសាររបស់ ប្រាក់ យុត?

**ឆៈ** ខ្ញុំឌុបគាត់ទៅបើកអង្គប្រជុំតាមឃុំ គាត់ដើរសន្និបាតតាមឃុំពីរឿងប្រជាជនលើកទំនប់ទៅ ប្រជាជនដាំដំណាំទៅ។ ហ្នឹងខ្ញុំឌុប ខ្ញុំឌុបទៅ គាត់អត់ចេះជិះកង់ទេ។

**សៈ** តើលោកស្រីធ្លាប់យកសំបុត្រពីគាត់ទៅឲ្យអ្នកណាម្នាក់ដែរឬទេ?

**ឆៈ** ធ្លាប់ គាត់ប្រើទៅ ក៏ខ្ញុំទៅៗ។ កាលណាគាត់មិនប្រើទេ ក៏ខ្ញុំនៅដេរខោអាវកងទ័ពនៅមន្ទីរស្រុកទៅ។ កាលណាគាត់ប្រើក៏ខ្ញុំទៅៗ ដើរទេ។ ជួនដើរទៅ ជួនក៏ជិះកង់ទៅតាមភ្លឺស្រែហ្នឹងទៅ។

**សៈ** តើលោកស្រីនៅចាំដែរឬទេ យកសំបុត្រទៅឲ្យអ្នកណា ឈ្មោះអីដែលថាយកទៅឲ្យក្នុងនាម ប្រាក់ យុត ហ្នឹង?

**ឆៈ** យកទៅឲ្យមេឃុំ។ ជួនកាល ក៏ឃុំកោះមិត្ត ទៅឃុំកោះទន្ទឹម ឃុំ តាមឃុំនីមួយៗ ពេលគេមកប្រជុំ។

[redacted]

**សៈ** បាទ អរគុណ។ ខ្ញុំសូមត្រឡប់ទៅសំណួរអំពីការប្រជុំ ឬក៏ជួបគ្នារវាង ប្រាក់ យុត និង តាម៉ុក។ តើលោកស្រីដឹងទេ ថាតើ តាម៉ុក និង ប្រាក់ យុត ហ្នឹងធ្លាប់ជួបគ្នា ឬក៏មានការប្រជុំអីដែរឬទេ នៅក្នុងតំបន់៤១?

[១៤:២៦:៣០]

**ឆៈ** គាត់អត់ -- គាត់មកប្រជុំមែន ប៉ុន្តែប្រជុំនៅស្រុកព្រៃឈរ ជាមួយ [redacted] ហ្នឹង គាត់អត់ដែលទៅកំពង់សៀមទេ។ គាត់តែពេលប្រជុំ គាត់មកស្រុកព្រៃឈរហ្នឹង។

**សៈ** ហើយតើ ប្រាក់ យុត បានចូលរួមការប្រជុំនៅព្រៃឈរដែរឬទេ?

**ឆៈ** បាន។

[redacted]

**សៈ** តើលោកស្រីបានដឹងពីការប្រជុំបែបនោះ ទាំងនោះ ដោយរបៀបណា?

**ឆៈ** ព្រោះគាត់ប្រជុំ មានមីក្រូ ជួនកាលក៏អត់ទៅ ខ្ញុំស្តាប់បាន ខ្ញុំព្រោះថា ខ្ញុំនីរសារសិទ្ធិនៅ

ក្រោមផ្ទះ។ ខ្ញុំឮបន្តិចបន្តួចតាមមីក្រូទៅ ក៏ខ្ញុំយកចិត្តទុកដាក់ទៅ។ ជួនកាល ក៏ខ្ញុំមិនយកចិត្តទុកដាក់ទៅ ព្រោះគេអ្នកធំ ព្រោះខ្ញុំសិទ្ធិជានីរសារ។

**ស៖** តាមអ្វីដែលខ្ញុំយល់ តើមានតែលោកស្រីជា -- ឌុប ប្រាក់ យុត ទៅចូលរួមប្រជុំ ហើយហេតុអ្វីបានជាលោកស្រីទៅនៅក្រោមផ្ទះ ផ្ទះនោះនៅកន្លែងណា?

**ឆ៖** ផ្ទះនៅព្រៃទទឹង ហើយគាត់ឡើងទៅប្រជុំទៅ ខ្ញុំនៅក្រោមផ្ទះ ខ្ញុំអត់មានសិទ្ធិទេ គេប្រជុំតែអ្នកធំ។

**ស៖** ប៉ុន្តែលោកស្រីនៅខាងក្រោមផ្ទះអ៊ីចឹងអ្ហេសកាលនុ៎ង?

**ឆ៖** ចាស។

**ស៖** តើលោកស្រីបានដឹង បានឮដែរឬទេ ថាការប្រជុំហ្នឹង គេនិយាយពីអ្វីខ្លះ ប្រធានពីអ្វីខ្លះដែលលោកស្រីបានឮហ្នឹង?

**ឆ៖** ខ្ញុំឮតែដឹកនាំឲ្យ ប្រាក់ យុត ហ្នឹងធ្វើការរកស៊ីបង្កបង្កើនផល។ បើរឿងថាសម្លាប់មនុស្សខ្ញុំអត់បានឮទេ។

[១៤:២៩:៣៦]

**ស៖** តើលោកស្រីអាចប៉ាន់ប្រមាណទេ ថាតើការប្រជុំហ្នឹង ញឹកញាប់ប៉ុនណាដែលជាការប្រជុំដែលចូលរួមដោយ ប្រាក់ យុត, តាម៉ុក ហើយនិង [redacted] រវាងមនុស្សប៉ុន្មាននាក់ហ្នឹង ញឹកញាប់ទេ ហើយប៉ុន្មានដង អាចប៉ាន់ប្រមាណបានទេ?

**ឆ៖** ក្នុងមួយខែៗ គឺបីបួនដង តាមគាត់នឹកឃើញ។

**ស៖** បាទ ឥឡូវនេះ ខ្ញុំចង់សួរលោកស្រីអំពីការប្រជុំទាំងឡាយ ឬក៏ដំណើរដែល ប្រាក់ យុត គាត់ធ្វើដំណើរមកភ្នំពេញ។ តើលោកស្រីដឹងទេ ប្រាក់ យុត ធ្លាប់ធ្វើដំណើរមកភ្នំពេញដែរឬទេ នៅពេលដែលលោកស្រីធ្វើការនៅតំបន់៤១?

**ឆ៖** គាត់មក ប៉ុន្តែគាត់ជិះឡានជាមួយ [redacted]។ គាត់ប្រាប់ថា គាត់មកប្រជុំ ប៉ុន្តែមិនដឹងប្រជុំឯណា ខ្ញុំអត់បានដឹងទេ។

**ស៖** បាទ ជាថ្មីម្តងទៀត គឺខ្ញុំស្តាប់ក្នុងការបកប្រែជាភាសាអង់គ្លេសមានន័យថា គាត់ហ្នឹងប្រុស តើលោកស្រីអាចបញ្ជាក់បានដែរទេ លោកស្រីនិយាយពី ប្រាក់ យុត ដែលធ្វើដំណើរមកជាមួយ [redacted] មកប្រជុំភ្នំពេញហ្នឹង គេថា ភាសាអង់គ្លេស "*ហ៊ី*"– គាត់ហ្នឹងវាប្រុស តើ ប្រាក់ យុត ហ្នឹងប្រុស ឬស្រី?

**ឆ៖** គឺគាត់ស្រី។

**ស៖** បាទ អរគុណ ហើយលោកស្រីថា ប្រាក់ យុត មកជិះឡានជាមួយ [redacted] មកភ្នំពេញ។ តើលោកស្រីបានដឹងថា ពួកគាត់ទាំងពីហ្នឹងមកធ្វើអីទេ នៅភ្នំពេញកាលនោះ?

**ឆ៖** គាត់ប្រាប់ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញមេធាវីការពារក្តីលោក ខៀវ សំផន!

[១៤:៣១:៤៧]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមសក្ខីកម្មរបស់សាក្សីបានឆ្លើយមុននេះបន្តិចហ្នឹង គាត់បានបញ្ជាក់ថា ប្រាក់ យុត ចេញមកប្រជុំ។ ជិះឡានជាមួយ [redacted] ប៉ុន្តែមិនដឹងថា មកភ្នំពេញ ឬទៅកន្លែងណាទេ។ ដូច្នេះ បើសិនជាសហព្រះរាជអាជ្ញារងចង់បញ្ជាក់សក្ខីកម្មនេះ ថាមកភ្នំពេញ ទាល់តែសួរបញ្ជាក់ឲ្យបានច្បាស់ បើលោកធ្វើការសន្និដ្ឋានថា ការប្រជុំនោះ ប្រាក់ យុត មកជាមួយ [redacted] មកប្រជុំនៅភ្នំពេញ គឺផ្ទុយពីសក្ខីកម្មរបស់សាក្សីហើយ។ បាទ សូមអរគុណ។

**លោក ត្រាវីស ហ្វារ៖**

ខ្ញុំសូមអធ្យាស្រ័យ ដោយសារអំនានរបស់ខ្ញុំទេ គឺធ្វើឲ្យច្រឡំ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកស្រីសាក្សី លោកស្រីបានជម្រាបជូនតុលាការថា ប្រាក់ យុត និង [redacted] បានជិះឡានជាមួយគ្នាមកប្រជុំនៅឯភ្នំពេញ តើលោកស្រីដឹងថា គេប្រជុំពីអ្វីដែរទេ នៅភ្នំពេញនោះ?

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** គឺខ្ញុំអត់បានដឹងដែរ ដឹងតែភ្នំពេញៗ មិនដឹងប្រជុំអីណាផង។

**ស៖** ចុះលោកស្រីដឹងថា ពេលមកដល់ភ្នំពេញហ្នឹង ពួកគាត់ទាំងពីរហ្នឹងជួបជាមួយអ្នកណាទេ?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះគាត់ថាប៉ុណ្ណឹង។ គាត់ថា មកភ្នំពេញៗ ប្រជុំ។ មិនដឹងអ្នកណាជាមេរបស់គាត់ ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកស្រីអាចប៉ាន់ប្រមាណបានទេថា ប្រាក់ យុត ហ្នឹងគាត់មកប្រជុំនៅភ្នំពេញហ្នឹង

បានប៉ុន្មានដងដែរ?

**ឆ៖** ខ្ញុំអត់បានជារាប់ទេ ព្រោះគាត់ធ្វើការយូរឆ្នាំដែរហើយ ព្រោះថា បន្តិចទៅប្រជុំៗ។ ខ្ញុំនៅឯផ្ទះអីនោះ ព្រោះថា គាត់មិនទើបមួយឆ្នាំ ពីរឆ្នាំទៅ ខ្ញុំនឹក ស្មានសន្និដ្ឋាន ប៉ុន្តែគាត់យូរហើយ តាំងពីខ្ញុំនៅក្មេងមកទាល់ដាច់យួនហ្នឹង។

**ស៖** ខ្ញុំដឹងហើយ ប្រហែលជាអាចពិបាកក្នុងការឆ្លើយប្រាប់ពីចំនួនកិច្ចប្រជុំជាសរុបហ្នឹង។ ប៉ុន្តែសូមប្រាប់មើលថា តើមកប្រជុំញឹកញាប់ដែរទេ មួយខែម្តង ពីរឆ្នាំម្តង ឬក៏មួយអាទិត្យម្តង? តើលោកស្រីអាចនឹកឃើញទេ?

**ឆ៖** ជួនណាគាត់មកមួយខែពីរដង ជួនណាគាត់មកមួយខែម្តង។ អាហ្នឹងតាមដែលតែគេកោះហៅរបស់គាត់។

[១៤:៣៤:៥៩]

**ស៖** សូមអរគុណ។ លោកស្រីបានឆ្លើយពីខាងដើមថា នៅពេលមួយនោះ លោកបានធ្វើជាប្រធានកងចល័តនៅពេលដែលលោកស្រីនៅឯស្រុកកំពង់សៀម។ តើនៅកងចល័តហ្នឹង លោកស្រីមានតួនាទីអ្វីដែរ? ហើយទទួលខុសត្រូវអ្វីដែរ?

**ឆ៖** ខ្ញុំទទួលកងចល័តហ្នឹង ប្រាក់ យុត ឲ្យកាន់ហ្នឹង ចំនួនចល័ត២០០នាក់ ដឹកនាំធ្វើស្រែ ស្ទូងដក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហព្រះរាជអាជ្ញារងអន្តរជាតិ។ បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំរបស់សាក្សី ដល់សាក្សីរូបនេះនៅអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ព្រមទាំងមេធាវីប្រឹក្សាសាក្សីរបស់គាត់ មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនៅវេលាម៉ោងបីខ្វះដប់នាទី។

បាទ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៦ នាទី ដល់ម៉ោង ១៤:៥៣ នាទី)*

[១៤:៥២:៤៥]

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ត្រាវីស ហ្វារ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ត្រាវីស ហ្វារ៖**

**ស៖** លោកស្រីសាក្សី មុនពេលយើងឈប់សម្រាកនេះ លោកស្រីបាននិយាយថា ប្រាក់ យុត មកភ្នំពេញមួយដង ឬក៏ពីរដងក្នុងមួយខែ នៅពេលដែលគេហៅគាត់មកប្រជុំ។ នៅពេលលោកស្រីថា គេហៅឲ្យមកប្រជុំ ធ្វើម៉េចបានជាលោកស្រីដឹងថា គេហៅគាត់ឲ្យមកប្រជុំ? ហើយអ្នកណាហៅគាត់ឲ្យមកប្រជុំ?

[១៤:៥៤:០៤]

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** គឺខ្ញុំអត់បានដឹងដែរ ព្រោះគាត់ប្រាប់ខ្ញុំថា គាត់ទៅប្រជុំភ្នំពេញ។

**ស៖** នៅពេល ប្រាក់ យុត ប្រាប់លោកស្រីថា គេហៅគាត់មកប្រជុំ តើលោកស្រីមានដឹងថា គាត់មានធ្លាប់បានមកចូលនៅក្នុងវគ្គរៀនសូត្រដែរទេ?

**ឆ៖** កាលណាគាត់មករៀនសូត្រគាត់ប្រាក់ខ្ញុំថា មក ១០ថ្ងៃ ឬមួយកន្លះខែ ហ្នឹងគាត់ប្រាប់ថា ទៅរៀនភ្នំពេញ ឯណាៗ ខ្ញុំអត់បានដឹងដែរ។

**ស៖** លោកស្រីបានឆ្លើយថា ពេលខ្លះគាត់មក ១០ថ្ងៃកន្លះ រៀនសូត្រ១០ថ្ងៃ កន្លះខែ។ តើលោកស្រីដឹងថា គេធ្វើឡើងនៅក្នុងពេលណា? នៅកន្លែងណាដែរទេ?

**ឆ៖** ខ្ញុំអត់បានដឹងផង។

**ស៖** តើ ប្រាក់ យុត ធ្លាប់និយាយប្រាប់លោកស្រីថានៅក្នុងវគ្គរៀនសូត្រហ្នឹងគេរៀនសូត្រអំពីអ្វីដែរទេ?

**ឆ៖** គាត់ទៅវិញ គាត់តែងតែនិយាយប្រាប់ខ្ញុំថាប្រជុំពីរឿងការងាររបស់ប្រជាជន គាត់ប្រាប់តែប៉ុណ្ណឹង។

**ស៖** តើគាត់ធ្លាប់ប្រាប់លោកស្រីលម្អិតដែរទេអំពីការងារប្រជាជនហ្នឹង? តើការងារប្រជាជនគាត់ចង់និយាយថាដូចម្ដេចដែរ?

**ឆ៖** គាត់ប្រាប់ខ្ញុំតែប៉ុណ្ណឹង ប៉ុន្តែខ្ញុំមិនបានដេញដោលគាត់ទេ ព្រោះខ្ញុំនៅសិទ្ធិជាក្រោមរបស់គាត់។

[១៤:៥៦:២៧]

**ស៖** ឥឡូវ ខ្ញុំសួរអំពីតួនាទីរបស់លោកស្រីមួយទៀត។ លោកស្រីបានឆ្លើយថា លោកស្រីជាសមាជិកគណៈកម្មាធិការឃុំ។ តើនៅក្នុងឃុំហ្នឹងលោកស្រីកាន់តួនាទីជាអ្វី? ហើយឃុំអីដែរ?

**ឆ៖** ខ្ញុំនៅក្នុងឃុំរអាង ជាអនុឃុំ កាន់ជាស្ត្រី ដើរស្ទូងដក។

**ស៖** ក្រៅពីកាន់កាប់ការងារស្ត្រីធ្វើការនៅស្ទូងដកហ្នឹង តើលោកស្រីមានតួនាទីអ្វីទៀតក្រៅពីនេះដែរ?

**ឆ៖** អត់មានផង ព្រោះការងារសំខាន់របស់មនុស្សប្រុស។

**ស៖** ឥឡូវនេះ ខ្ញុំសួរលោកស្រីអំពីជនជាតិចាមនៅក្នុងស្រុកកំពង់សៀម។ សូមលោកស្រីរៀបរាប់ជូនតុលាការជាទូទៅសិនមើល៍ នៅពេលដែលលោកស្រីបានទៅដល់ស្រុកកំពង់សៀមហ្នឹង ចេញពីភូមិនិរតីហ្នឹង តើមានជនជាតិចាមរស់នៅក្នុងស្រុកកំពង់សៀមទេ?

**ឆ៖** គឺមានៗនៅក្បែរមាត់ទន្លេ។

**ស៖** ហើយតើលោកស្រីអាចជម្រាបជូនតុលាការជាទូទៅបានទេ មានអ្វីកើតឡើងទៅដល់ជនជាតិចាមទាំងនោះនៅពេលដែលលោកស្រីធ្វើការនៅក្នុងស្រុកកំពង់សៀម?

**ឆ៖** ខ្ញុំមិនដឹងរឿងអីដែរ ព្រោះគេថាបោសសម្អាត។

**ស៖** អ្នកណាប្រាប់លោកស្រីថា គេត្រូវបោសសម្អាតហ្នឹង?

**ឆ៖** មេកងទ័ពស្រុក។

**ស៖** តើអ្នក -- ឱ្យចំតែម្ដង អ្នកណាជាអ្នកប្រាប់ហ្នឹង? ផុន ឬក៏ ផែន?

**ផ៖** ផុន។

[១៤:៥៩:០៨]

**ស៖** នៅពេលនុ៎ង តើពាក្យ "បោសសម្អាត" មានន័យថាដូចម្តេចដែរសម្រាប់ស្រុកកំពង់សៀម ហ្នឹង?

**ផ៖** ព្រោះគេធ្វើបញ្ជីមានសមាសភាព។ ខ្ញុំហ្នឹងទៅវាយអង្គុលីលេខ ទៅបូកទៅ ឃើញអ៊ីចឹង មែន។

**ស៖** ឥឡូវសូមសួរលម្អិតអំពីបញ្ជីឈ្មោះមនុស្សនេះ។ តើអ្នកណាជាអ្នកស្នើ ឬក៏ជាអ្នកបញ្ជាឲ្យ លោកស្រីរៀបចំបញ្ជីឈ្មោះនេះ?

**ផ៖** គឺ ប្រាក់ យុត។

**ស៖** ហើយនៅពេលដែល ប្រាក់ យុត ស្នើឬក៏បញ្ជាឲ្យលោកស្រីរៀបចំបញ្ជីហ្នឹង គឺបញ្ជាឲ្យ ស្រីនៅឯណា? បញ្ជានៅក្នុងមន្ទីរ? បញ្ជានៅតាមផ្ទះ? ឬក៏បញ្ជាពេលលោកស្រីនៅកន្លែងណា?

**ផ៖** ជួនកាលគាត់ហៅខ្ញុំពីឃុំរអាងមកមន្ទីរស្រុកក៏មាន។ ឬមួយក៏ខ្ញុំ -- គាត់ទៅកន្លែងខ្ញុំធ្វើការ កំពុងស្ទូងដកក៏មាន។ ជួនកាលគាត់មកប្រជុំនៅក្នុងមន្ទីរស្រុកក៏មាន។

**ស៖** នៅពេលដែលលោកស្រីរៀបចំបញ្ជីឈ្មោះនុ៎ង តើមានអ្នកណាចូលរួមនៅក្នុងការទទួល បញ្ជាហ្នឹងដែរទេ ឬក៏តែលោកស្រីទទួលបញ្ជាតែពី ប្រាក់ យុត តទល់តែម្តង? ឬក៏មានអ្នកផ្សេងចូលរួម ដែរ?

**ផ៖** មានប្រធានមន្ទីរស្រុកគឺ ណន គាត់អ្នកជួយជំនាញការខាងវាយអង្គុលីលេខ។

**ស៖** តើប្រជាជនប្រភេទណាដែលលោកស្រីរៀបចំបញ្ជីឈ្មោះហ្នឹង?

**ផ៖** គឺមានឃើញតែពួកទាហានចាស់ៗជំនាន់ សីហនុ មានជនជាតិចាម មានជនជាតិយួន។

**ស៖** តើ ប្រាក់ យុត ឬក៏អ្នកណាម្នាក់ធ្លាប់បានប្រាប់លោកស្រីថា ត្រូវរៀប ចាំបាច់ត្រូវរៀបចំ បញ្ជីហ្នឹងទេ មូលហេតុអីទេ?

**ផ៖** ខ្ញុំមិនបានសួរដែរ ព្រោះគាត់បញ្ជាអ៊ីចឹង ខ្ញុំធ្វើតាមគាត់ទៅ។

**ស៖** នៅពេលលោកស្រីរៀបចំបញ្ជីឈ្មោះហ្នឹង គឺបញ្ជីឈ្មោះលោកស្រីបាននិយាយថា បញ្ជី ឈ្មោះអតីតទាហានរបប លន់ នល់។ តើបញ្ជីសម្រាប់បញ្ជីឈ្មោះទាហាន អតីតទាហានរបប សីហនុ ហ្នឹង តើគេរៀបចំសម្រាប់តែមានអ្នកឋានន្តរសក្តិ ឬក៏គេរៀបចំទូទៅ?

ផ៖ គេរៀបចំទូទៅ មានមួយភូមិប៉ុន្មាន មានម៉ានេះប៉ុន្មាន មួយក្រុមប៉ុន្មានអ៊ីចឹង។ គេដកស្រង់យកតាមភូមិ។

[១៥:០៣:១៦]

ស៖ នៅពេលលោករៀបចំបញ្ជីចំនួនអតីតទាហានរបបមុនហ្នឹង តើគេយកតែឈ្មោះទាហានៗហ្នឹងទេ? ឬក៏រៀបចំបញ្ជីឈ្មោះទាំងក្រុមគ្រួសារទាហាននោះតែម្ដង?

ផ៖ ហ្នឹង ខ្ញុំមិនសូវដឹងដែរ។ វាធ្វើតែ ផ្ទះនេះធ្វើទាហាន រាប់តែឪពុកម្ដាយទៅ។ ក្នុងមួយគ្រួសារប៉ុន្មានហ្នឹង ក៏អត់ដឹងដែរ។ ដឹងដែរ ដូចថាពូនេះធ្វើទាហាន ប្រពន្ធទាហានតែប៉ុណ្ណឹងទេ។

ស៖ ចុះចំពោះជនជាតិចាមវិញ លោកស្រីរៀបចំបញ្ជីឈ្មោះហ្នឹង តែឪពុកម្ដាយទេឬ? ឬក៏រៀបចំបញ្ជីឈ្មោះទាំងកូនៗផងដែរ?

ផ៖ អត់ទេ ធ្វើតែឪពុកម្ដាយគេទេ។ កូនអត់មានគិតទេ។

ស៖ ចុះជនជាតិវៀតណាមវិញ យ៉ាងម៉េចដែរ?

ផ៖ ធ្វើអ៊ីចឹងដូចគ្នាទាំងអស់។

ស៖ តើលោក -- សុំលោកស្រីរៀបរាប់ជូនតុលាការមើល តើធ្វើម៉េចបានជាលោកស្រីអាចរៀបចំឈ្មោះ បញ្ជីឈ្មោះអតីតទាហាន និងជនជាតិចាម និងជនជាតិវៀតណាមទៅបាន? ម៉េចបានលោកស្រីធ្វើទៅកើត?

ផ៖ គឺធ្វើហ្នឹងធ្វើតាមរបាយការណ៍របស់ប្រធានភូមិឲ្យមក។ មួយភូមិមានប៉ុន្មានៗ កត់ចម្លងតាមហ្នឹងទៅ។

ស៖ តើបញ្ជីឈ្មោះនេះ គេរៀបចំសម្រាប់តែឃុំណាមួយជាក់លាក់ ឬក៏គេរៀបចំបញ្ជីឈ្មោះនេះ នៅទូទាំងស្រុកកំពង់សៀមតែម្ដង?

ផ៖ ចាស ទូទាំងស្រុក។

ស៖ លោកស្រីនៅចាំបានទេថា ពេលហ្នឹងលោកស្រីរៀបចំបញ្ជីឈ្មោះហ្នឹង គិតទៅប៉ុន្មាននាក់ដែរ?

ផ៖ ខ្ញុំស្មានថា ចំនួនជា៣០០។

ស៖ ក្រោយពីរៀបចំបញ្ជីឈ្មោះ មនុស្សទាំង ៣០០នាក់នេះរួចរាល់ហើយ តើគេចាត់ការយ៉ាងម៉េចជាមួយអ្នកទាំងនេះ?

**ឆ៖** ខ្ញុំអត់ដឹងដែរ អាហ្នឹងនៅលើ[redacted]និង ប្រាក់ យុត ហ្នឹង គេចាត់ការ។

[redacted]

[១៥:០៨:២៥]

[redacted]

**ស៖** ក្រៅពីចំណារនេះ លោកស្រីដែលដឹងថា គេបានបញ្ជូនឈ្មោះដែលគេចារហ្នឹងទៅថ្នាក់តំបន់ទេ មានអ្នកណាដែលត្រូវបញ្ជូនថ្នាក់តំបន់ ដែលដឹងទេ? ហើយដឹងថាអ្នកណាត្រូវគេសម្លាប់ចោលនៅថ្នាក់ស្រុកទេ?

**ឆ៖** ខ្ញុំអត់បានៗដឹងទេ ព្រោះរឿងហ្នឹង គេធ្វើការយប់ ខ្ញុំធ្វើការថ្ងៃ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា បាត់មនុស្សបន្តបន្ទាប់។

[១៥:១១:៤៩]

**ស៖** នៅពេលលោកស្រីថា បាត់មនុស្សជាបន្តបន្ទាប់ហ្នឹង លោកស្រីចង់និយាយថា បាត់មនុស្សទាំងបីក្រុមហ្នឹងអ្នេស គឺអតីតទាហាន ចាម និងជនជាតិវៀតណាម?

**ឆ៖** និយាយរួម គឺខ្ញុំឆ្លល់ បាត់មនុស្សដែលជាប់សមាសភាពចូលក្នុងបញ្ជីហ្នឹងតែម្តង។

**ស៖** លោកស្រីដឹងថា អ្នកចាប់ខ្លួន ជាអ្នកណាទេ?

**ឆ៖** ខ្ញុំដឹងតែមានតែកងទ័ពស្រុក និងកងទ័ពតំបន់ រួមដៃជាមួយគ្នា។

**ស៖** ធ្វើម៉េចបានជាលោកស្រីដឹងថា ទ័ពស្រុក និងទ័ពតំបន់រួមដៃគ្នាចាប់ប្រជាជនទាំងនោះ?

**ឆ៖** ព្រោះ ខុម ហ្នឹងនិយាយប្រាប់ខ្ញុំ ព្រោះអាហ្នឹងវាត្រង់ វាឆ្ងល់ដែរ។ ល្ងាចឡើង ពួកទាហានតំបន់ វាចុះមកស្រុក ខុម ហ្នឹងវាដឹង ខ្ញុំមិនសូវដឹងទេ ព្រោះខ្ញុំនៅជនបទ វានៅមន្ទីរស្រុក។ ដល់ពេលនេះ វាប្រាប់រឿង។ តែប៉ុណ្ណឹង។

**ស៖** ចុះលោកស្រីដែលធ្លាប់បានដឹងថា ប្រាក់ យុត នេះ ចូលរួមពាក់ព័ន្ធក្នុងការចាប់ខ្លួនហ្នឹងដែរទេ? ចូលរួមជាមួយនឹងកងទ័ព ឬក៏ផ្តល់ព័ត៌មានបន្ថែមទៅឲ្យកងទ័ព ក្នុង -- គាត់ចូលរួមពាក់ព័ន្ធក្នុងការចាប់ខ្លួនទាំងនេះដែរទេ?

**ឆ៖** ព្រោះខ្ញុំ ព្រោះថា ខ្ញុំគិតថា គាត់ខ្លាចខ្មោច គាត់មិនបានចាប់អារម្មណ៍រឿងអីចឹងៗទេ។ ខ្ញុំទុកចិត្តគាត់។

[១៥:១៤:២៧]

**ស៖** ឥឡូវលោកស្រីនិយាយអំពីការបាត់ខ្លួនមនុស្សដែលមាននៅក្នុងបញ្ជី។ តើពេលបាត់ខ្លួនហ្នឹង តើបាត់ខ្លួនតែមនុស្សដែលមានឈ្មោះនៅក្នុងបញ្ជី ឬក៏បាត់ខ្លួនទាំងសមាជិកគ្រួសាររបស់ពួកគេផងដែរ?

**ឆ៖** គឺបាត់តែក្នុងបញ្ជីទេ។

**ស៖** ឧទាហរណ៍ ក្នុងស្ថានភាពមួយដែលទាំងឪពុកទាំងម្ដាយជាជនជាតិចាមមានឈ្មោះនៅក្នុងបញ្ជី តើបាត់ឈ្មោះតែឪពុកម្ដាយពីរនាក់ហ្នឹង ឬក៏បាត់ទាំងសមាជិកគ្រួសារគេផងដែរ?

**ឆ៖** ខ្លះណាក៏បាត់ទាំងកូនចៅទៅ ខ្លះណាក៏បាត់តែម៉ែឪទៅ នៅកូនចេចចាចហ្នឹង ក៏ប្រធានភូមិយកទៅចិញ្ចឹមទៅ ទៅរែកដីទៅ ទៅធ្វើការក្នុងកងទៅនៅមន្ទីរបាយទៅ តាមដំណើររបស់គេទៅ។

[redacted]

[១៥:១៧:២៧]

[redacted]

**ស៖** ខ្ញុំសូមបន្តសួរទៅប្រធានបទថ្មីមួយទៀត។ ក្រោយពីលោក -- លោកស្រីរៀបចំបញ្ជីលើកដំបូងនេះរួចមក តើលោកស្រីធ្លាប់បានចូលរួមប្រជុំជាមួយ [redacted] ឬក៏ថាធ្លាប់បានទទួលបញ្ជាអីមួយពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះលើកទី២ទេ?

**ឆ៖** អត់ដែលផង។

[១៥:១៩:៥៦]

[redacted]

[១៥:២២:៤៩]

[redacted]

[redacted]

**សៈ** តើលោកស្រីនៅចាំឈ្មោះតំណាងមកស្រុកកងមាសចូលរួមនៅក្នុងអង្គប្រជុំនោះដែរទេ? នៅចាំឈ្មោះទេ?

**ឆៈ** គឺខ្ញុំអត់បានស្គាល់គេច្រើនទេ ព្រោះខ្ញុំថា ខ្ញុំរវល់នៅមន្ទីរស្រុក។ ខ្ញុំធ្វើអនុឃុំផង ខ្ញុំដឹកនាំដោយ ប្រាក់ យុត ផង។ ខ្ញុំរវល់ដែរ។

**សៈ** សំណួរបន្ទាប់នេះ គឺទៅលើសេចក្តីព្រាងប្រតិចារឹកនៅថ្ងៃទី១២ ខែមករា នៅម៉ោងដប់កន្លះព្រឹក ម៉ោងដប់១០:៣៧នាទីព្រឹក។ លោកស្រីសាក្សី តើលោកស្រីនៅចាំឈ្មោះនារីម្នាក់ឈ្មោះ ភាព ដែលក្រោយមកក្លាយទៅជាមេឃុំពាមជីកង ក្នុងស្រុកកងមាស ហើយនារីនេះគឺជាប្រពន្ធរបស់មេស្រុកកងមាសឈ្មោះ កាន។ លោកស្រីនៅចាំឈ្មោះនារីម្នាក់នេះទេ?

**ឆៈ** ខ្ញុំអត់បានស្គាល់ផង។

[redacted]

**សៈ** ហើយតើលោកស្រីនៅចាំបានទេថា បញ្ជីលើកទី២នេះ គេរៀបរាប់ -- គឺបញ្ជីលើកទី២នេះរាប់បញ្ចូលឈ្មោះប្រជាជនប្រភេទណាដែរ?

**ឆៈ** គេគ្រាន់តែប្រជុំ គេដាក់មីក្រូ គេប្រកាសឲ្យយើងរើសពួកសមាសភាព បោសសម្អាតមួយសាទៀត។ ប៉ុន្តែមិនទាន់បានបោសសម្អាតទេ ហើយមិនទាន់បានធ្វើបញ្ជីទេ ក៏វៀតណាមចូលមកទៅ។

**សៈ** អ្នកណាណែនាំឲ្យលោកស្រីបោសសម្អាតប្រជាជនដោយប្រកាសតាមមីក្រូនេះ? អ្នកណាហ្នឹង?

[redacted]

[redacted]

[១៥:២៦:៥០]

**សៈ** ហើយតើអ្នកទាំងពីរហ្នឹងគេនិយាយឲ្យបោសសម្អាតហ្នឹងសំដៅទៅលើមនុស្សប្រភេទណា?

**ឆៈ** ឲ្យតែមនុស្សជាប់ជនជាតិ ជាប់សមាសភាព ដកស្រង់បញ្ជីទាំងអស់។

[redacted]

[redacted]

**សៈ** តើលោកស្រីអាចជម្រាបជូនតុលាការបានទេ អង្គប្រជុំមួយហ្នឹង នៅក្រោយហ្នឹងមានមនុស្សចូលរួមប៉ុន្មាននាក់ដែរ?

**ឆៈ** ប្រជុំឯណាលើកក្រោយ? ប្រជុំនៅខាងតំបន់ហ្នឹងក៏មាន ប្រជុំនៅខាងស្រុកក៏មាន ប៉ុន្តែខ្ញុំមិនដឹងថាប៉ុន្មានទេ ព្រោះគេរើសតាមស្រុកអ្នកធ្វើការធំៗ ជួនកាលប្រធានភូមិ ជួនកាលក៏មេឃុំក៏ឡើងមក គេរើសទាំងអស់ ព្រោះខ្ញុំសិទ្ធិជានីរសារអត់ដឹងចំនួនទេ។

**សៈ** ខ្ញុំសូមសួរឡើងវិញហើយសួរឲ្យចំៗចំណុចតែម្តង។ លោកស្រីទើបតែបានរៀបរាប់អំពីការប្រជុំមួយដែល តាម៉ុក និង [redacted] ប្រើប្រាស់មីក្រូ ហើយនិយាយថា "អ្នកដែលមានជនជាតិផ្សេងនិងសមាសធាតុដទៃទៀតគឺថា ត្រូវតែបោសសម្អាត"។ នេះខ្ញុំចង់សំដៅទៅលើកិច្ចប្រជុំមួយនេះ លោកស្រីដឹងថានៅក្នុងកិច្ចប្រជុំមួយនេះមានមនុស្សចូលរួមប្រជុំប៉ុន្មាននាក់ដែរ?

**ឆៈ** គឺគាត់រើសតាមដូចថា បីឃុំ គាត់ធ្វើមីទ្ទិងម្តង ក្នុងមួយអាទិត្យ។

[១៥:៣០:០០]

**សៈ** ខ្ញុំខ្លាចតែខ្ញុំយល់មិនបានច្បាស់។ លោកស្រីទើបតែបានរៀបរាប់អំពីកិច្ចប្រជុំជាក់លាក់មួយដែលក្នុងកិច្ចប្រជុំនេះ តាម៉ុក និង [redacted] ហ្នឹងគឺនិយាយតាមមីក្រូប្រាប់ទៅអ្នកចូលរួមប្រជុំហ្នឹងថា

សមាសភាពទាំងអស់ ហើយនិងអ្នកដែលមានជាតិសាសន៍ផ្សេងនោះត្រូវតែបោសសម្អាត។ តើកិច្ចប្រជុំរៀបបៀបនេះ គេមានរៀបចំធ្វើឡើងញឹកញាប់ដែរទេ ឬក៏នេះជាលើកកិច្ចប្រជុំតែម្តងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប! អញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ តាមខ្ញុំស្តាប់បាន សក្ខីកម្មរបស់សាក្សីបានបញ្ជាក់ថា [redacted] និង តាម៉ុក ហ្នឹងឲ្យប្រជុំធ្វើបញ្ជីលើកទី២ ជាងជាការធ្វើបញ្ជីត្រួតពិនិត្យទៅលើសមាសភាពមិនល្អ ហើយមិនមានបញ្ជាក់ថា ដើម្បីបោសសម្អាតទេ គឺជាការធ្វើបញ្ជីជាលើកទី២។ អ៊ីចឹងថាតើត្រូវបោសសម្អាតឬអត់នោះ គឺសាក្សីមិនទាន់បាននិយាយនៅចំណុចនេះនៅឡើយទេ បាទ។ សូមអរគុណ។

**សួរដោយលោក ត្រាវីស ហ្វារ៖**

លោកប្រធាន ខ្ញុំបានយល់សាក្សីគាត់បានប្រើពាក្យថា "បោសសម្អាត" ហើយគាត់និយាយពីក្រុមមនុស្សជាតិពន្ធុផ្សេងៗផងដែរ។ ដូច្នេះ ខ្ញុំសុំការអនុញ្ញាតសួរសំណួរនេះឡើងវិញ ក្នុងករណីដែលគាត់មិនចាំសំណួរ។

**ស៖** លោកស្រីសាក្សី យើងបាននិយាយពីការប្រជុំមួយ។ ខ្ញុំជឿថាលោកស្រីបាននិយាយថា តាម៉ុក និង [redacted] បានប្រើមីក្រូ ហើយនិយាយថា សមាសភាពទាំងអស់ ហើយនិងប្រជាជនជាតិពិន្ទុផ្សេងៗទាំងអស់នឹងត្រូវបោសសម្អាត។ តើតាមភស្តុតាង និងសម្តីលោកស្រីនិយាយខាងដើមហ្នឹងមានន័យអ៊ីចឹងដែរឬទេ?

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** មានមែន។

[១៥:៣២:១៩]

**ស៖** សូមអរគុណដែលបានបំភ្លឺ។ ឥឡូវនេះ យើងផ្តោតអារម្មណ៍ទៅលើការប្រជុំមួយនេះថា តើលោកស្រីចាំទេ មានមនុស្សប៉ុន្មានដែលចូលរួមនៅក្នុងការប្រជុំហ្នឹង?

**ឆ៖** គាត់រើសមេឃុំមួយតំបន់ហ្នឹងតែហ្នឹង និយាយរួម មេឃុំៗយកមកប្រជុំគាត់ប្រកាសអ៊ីចឹងតែហ្នឹង។

**ស៖** បាទ សូមអរគុណចំពោះការបំភ្លឺនេះ។ តើលោកស្រីដឹងដែរឬទេថា តើប្រធាន ឬក៏មេ

របស់ តាអាន ហ្នឹងជាអ្នកណាបាទ?

**ឆ៖** គឺ តាម៉ុក។

**ស៖** ខ្ញុំនឹងប្តូរទៅប្រធានបទមួយទៀត គឺនិយាយអំពីការរៀបការ។ ដើម្បីចាប់ផ្តើម សូមលោកស្រីជម្រាបតុលាការថា តើអ្នកណាជាអ្នកផ្តល់ការយល់ព្រមឲ្យបុរស និងស្ត្រីរៀបការនៅកាលនោះ នៅក្នុងស្រុកកំពង់សៀម កាលដែលលោកស្រីនៅទៅនោះៗ?

**ឆ៖** គឺបុរសនិងស្ត្រី វានៅកងចល័ត ប៉ុន្តែវាត្រូវតម្រូវគ្នាទៅ វាស្នើដល់ប្រធានភូមិ ប្រធានភូមិក៏ប្រាប់ដល់ប្រធានឃុំ ប្រធានឃុំក៏ប្រាប់ដល់មេស្រុក ក៏នាំគ្នាកោះហៅយករៀបការនៅមន្ទីរស្រុកទៅ។

**ស៖** តើត្រឹមត្រូវដែរឬទេ គឺអាជ្ញាធរជាអ្នកសម្រេចឲ្យប្រជាជនរៀបការនាពេលនោះ?

**ឆ៖** ដូចខ្ញុំអត់បានយល់ ប៉ុណ្ណឹងខ្ញុំថាត្រឹមត្រូវ វាអត់មានឧប្បត្តិហេតុអី។

**ស៖** បាទ សូមអរគុណ។ កាលណាគេយល់ព្រមឲ្យរៀបការ ថាតើអ្នកណាជាអ្នកធ្វើអធិបតីនៅក្នុងពិធីរៀបការទាំងនោះ?

**ឆ៖** គឺ ប្រាក់ យុត ហើយនិងប្រធានភូមិ។ ភូមិណាដែលមានគូស្វាមីយកមករៀបទៅ ភូមិនោះនាំគ្នាមកៗ ក៏ ប្រាក់ យុត ហ្នឹងរៀបឲ្យទៅ។

[១៥:៣៥:១៥]

[redacted]

**ស៖** តើមានវិន័យ ឬក៏មានវិធានអ្វីដែរទេ ថាអ្នកណាត្រូវរៀបការជាមួយអ្នកណា? ដូចជាប្រជាជនចាម ហើយនិងកូនៗរបស់អតីតទាហានលន់នល់ តើមានវិន័យក្រឹត្យក្រមអីថាអ្នកណាត្រូវរៀបការជាមួយអ្នកណាដែរទេ តាមដែលលោកស្រីចាំ?

**ឆ៖** គឺគាត់រើស ថាខ្មែររៀបដោយខ្មែរ ចាមរៀបដោយចាម កុំឲ្យវាពាក់ព័ន្ធសមាសភាព។

**ស៖** ចុះពួកកូនៗរបស់អតីតទាហានលន់ នល់ តើអង្គការ ឬក៏ត្រូវបានគេអនុញ្ញាតឲ្យរៀបការដែរទេ?

ឆ៖ អាហ្នឹងខ្ញុំអត់បានដឹងផង ព្រោះអត់ដែលឮពួកហ្នឹងនិយាយ។

ស៖ នៅក្នុងចម្លើយចុងក្រោយរបស់លោកស្រី លោកស្រីនិយាយថា គាត់មិនចង់ឲ្យលាយឡំពួកសមាសភាពនោះ តើមានអត្ថន័យដូចម្ដេច?

ឆ៖ គឺខ្ញុំយល់ថា កុំឲ្យវាជាប់ពូជសាសន៍។

ស៖ តើលោកស្រីដឹងទេ អ្នកណាជាអ្នកដាក់វិធានវិន័យបែបនេះ?

ឆ៖ គឺ ប្រាក់ យុត។

[redacted]

[១៥:៣៨:៤១]

ស៖ តើលោកស្រីធ្លាប់បានដឹងដែរឬទេ ដែលថា ករណីដែលគូស្រករដែលគេរៀបការរួចហើយគឺអាចប្ដីនិងប្រពន្ធមិនចុងសម្រុង បានន័យថា មិនចង់រួមដំណេកជាមួយគ្នា។ លោកស្រីធ្លាប់ឮទេ ករណីហ្នឹង?

ឆ៖ គឺខ្ញុំអត់បានឃើញអីផង ព្រោះមនុស្សហ្នឹងនៅរួមគ្នា ទាល់ឥឡូវ បច្ចុប្បន្ន។

[redacted]

**ស៖** តើលោកស្រីដឹងដែរឬទេថា អ្នកណាជាអ្នកចេញវិធាន ឬបទបញ្ជាថា ក្រោយពីការហើយ ប្ដីប្រពន្ធត្រូវតែដេកនៅជាមួយគ្នា រួមដំណេក?

**ឆ៖** គឺប្រធានភូមិ ទាក់ទងនឹងប្រធានស្រុក គេអ្នកបញ្ជូនមក គេដឹក -- គេណែនាំគ្នាទៅឲ្យតាមដាន គឺ ប្រាក់ យុត ហ្នឹងតែម្ដង។

[redacted]

[១៥:៤២:០១]

**ស៖** យើងបានពិភាក្សាពីករណីមួយដែលថា ប្ដីប្រពន្ធយល់ស្របថា ថានឹងរួមដំណេកបន្ទាប់ពីពិភាក្សាជាមួយមេភូមិ។ តើលោកស្រីធ្លាប់ដឹងពីករណីដែលថា មានប្ដីប្រពន្ធណាមួយ ក្រោយពីមេភូមិអប់រំហើយ នៅតែមិនព្រមរួមដំណេកទៀត តើមានទេ?

**ឆ៖** មាន ប៉ុន្តែអប់រំមួយដង ជាពីរដងអ៊ីចឹងទៅ ក៏វាព្រមទៅ វាអត់មានបាក់បែកគ្នាទេ។

[redacted]

[redacted]

**ស៖** តើលោកស្រីនៅចាំដែរឬទេ ពេលដែលលោកស្រីស្គាល់គាត់ហ្នឹង ថាតើគាត់ខ្លួនឯងនោះបានរៀបការដែរឬទេ? តើការរៀបការហ្នឹងយ៉ាងដូចម្ដេច ហើយប្រតិកម្មដែលគាត់មាននៅពេលនោះយ៉ាងដូចម្ដេចដែរ?

**ឆ៖** ការរៀបការហ្នឹង ខ្ញុំក៏បានចូលរួមដែរ ព្រោះខ្ញុំមិនទាន់រៀបការទេ ខ្ញុំនៅលីវទេ។ គាត់គ្រាន់ផ្ដាំផ្ញើថា យើងខំប្រឹងប្រែងកសាងជាតិ ចម្រើនជាតិ និងប្រឹងប្រែងធ្វើការ តែប៉ុណ្ណឹងទេ។

**ស៖** តើៗគាត់និយាយប្រាប់ ឬក៏សម្ដែងដូចម្ដេចដែលថាឲ្យលោកស្រីអាចដឹងសប្បាយ ឬក៏រីករាយនៅក្នុងការរៀបការនៅពេលនោះ ហើយនិងចុះសម្រុងជាមួយប្ដីគាត់ ឬក៏មិនចុះសម្រុងដែរឬទេ?

**ឆ៖** ចាស គាត់រីករាយ គាត់សប្បាយនឹងដាំបាយ ជប់លៀង បន្តិចបន្តួច។

[១៥:៤៥:៥៨]

[redacted]

[redacted]

**លោក ត្រាវិស ហ្វារ៖**

សូមអរគុណលោកស្រីសាក្សី។ ខ្ញុំមិនមានសំណួរអ្វីទៀតទេ សូមអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីផ្ដល់វេទិកាទៅសហសេវិករបស់ខ្ញុំដើម្បីសួរបន្ត បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញសហ -- សូមអញ្ជើញបាទ ប្រគល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះម៉ារី ហ្គីរ៉ូដ៍ ខ្ញុំជាតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកស្រីនៅរសៀលនេះ ហើយនិងនៅថ្ងៃចន្ទព្រឹក។ នៅពេលដំបូងលោកស្រីបាននិយាយថា លោកស្រីត្រូវបានគេបញ្ជូនពីកំពតទៅកំពង់សៀម តើគេមានបានពន្យល់ប្រាប់លោកស្រីទេថា ហេតុអ្វីបានជាគេត្រូវបញ្ជូនលោកស្រីទៅកាន់ស្រុកកំពង់សៀមនោះ?

[១៥:៤៩:២៥]

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** គេប្រាប់ថាទៅធ្វើការ ប៉ុនមិនដឹងធ្វើការអីទេ ខ្ញុំចេះតែមកតាមគេទៅ។

**ស៖** សូមអរគុណ។ មុននេះលោកស្រីបានពន្យល់ថាពេលលោកស្រីទៅដល់កំពង់សៀម មានជនជាតិចាម ហើយលោកស្រីថាចាមរស់នៅតាមមាត់ទន្លេ ដូច្នេះខ្ញុំចង់ដឹងថាចាមហ្នឹងរស់នៅក្នុងភូមិដាច់ដោយឡែកពីខ្មែរ ឬក៏រស់នៅក្នុងភូមិនៅលាយឡំជាមួយនឹងខ្មែរ នៅក្នុងស្រុកកំពង់សៀមនោះ?

**ឆ៖** ចាស ជនជាតិចាមវានៅតាមមាត់ទន្លេ នៅឃុំគគរ នៅកោះទន្ទឹម ហ្នឹងចាមចូលចិត្តខាងផ្នែកត្រី។ រួចទៅវានៅលាយឡំនឹងខ្មែរយើងបានជា ប្រាក់ យុត ហ្នឹង ឲ្យដកស្រង់ដើម្បីឲ្យដឹងថា ណាចាម ណាខ្មែរ។

**ស៖** បញ្ជីដែលលោកជួយវាយអង្គុលីលេខហ្នឹង ហើយលោកថា លោកស្រីថាមានឈ្មោះ ៣០០

នាក់ ដូច្នេះនៅថ្ងៃនេះ តើលោកអាច លោកស្រីអាចចាំបានទេ ថាតើនៅក្នុងបញ្ជីហ្នឹង មានជនជាតិចាមប៉ុន្មានភាគរាយ? ខ្មែរប៉ុន្មានភាគរយ? ហើយអតីតមន្ត្រីរដ្ឋការប៉ុន្មានភាគរយដែរ នៅក្នុងចំណោមឈ្មោះទាំង៣០០នាក់ដែលលោកស្រីជួយវាយអង្គុលីលេខហ្នឹង?

**ឆ៖** វាយូរហើយខ្ញុំមិនបានចាំទេ គ្រាន់ដឹងតែចំនួន ដឹងចំនួនសរុបទាំងអស់ហ្នឹង ខ្ញុំបានចាំតែប៉ុណ្ណឹង។

**ស៖** អម្បាញ់មិញនេះ លោកនិយាយអំពីមនុស្សបីប្រភេទគឺទាហានសីហនុ វៀតណាម និងជនជាតិចាម--

[១៥:៥១:៥៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី វិចទ័រ កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

[redacted]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

លោកប្រធាន ខ្ញុំផ្អែកផ្ទាល់ទៅលើសក្ខីកម្មផ្ទាល់មាត់របស់លោកស្រីសាក្សីនៅថ្ងៃនេះ ហើយមេធាវីការពារក្តីគាត់មានសិទ្ធិសួរចំណុចនេះនៅពេលដល់វេណគាត់។ ខ្ញុំៗសួរដល់សាក្សីថាតើគាត់ចាំអំពីភាគរយនៃជនជាតិចាមដែលមាននៅក្នុងបញ្ជីឬក៏អត់ ហើយខ្ញុំក៏មិនបានសួរអំពីប្រភេទផ្សេងទៀតដែរ។

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៏៖**

**ស៖** លោកសាក្សី តើលោកស្រីចាំទេ ថានៅសម័យនោះ ជនជាតិចាមមានប៉ុន្មានភាគរយដែរនៅក្នុងបញ្ជីឈ្មោះដែលមានមនុស្ស៣០០នាក់នោះ?

**លោកស្រី យូ វ៉ាន់៖**

**ឆ៖** គឺខ្ញុំអត់បានចាំទេ។

**ស៖** តើលោកស្រីដឹងទេថា ជនជាតិចាមដែលលោកស្រីស្រង់ឈ្មោះហ្នឹង ជាចាមដែលរស់នៅស្រុកកំពង់សៀមតាំងពីយូរណាស់មកហើយ ឬក៏មានតែជនជាតិចាមដែលទើបតែត្រូវបានបញ្ជូនមកកាន់ស្រុកកំពង់សៀមនោះ? តើលោកស្រីដឹងទេ?

**ឆ៖** គឺជនជាតិចាមហ្នឹង នៅតាំងពីជំនាន់សីហនុដែរ។ បើជនជាតិចាមថ្មីគ្មានទេ នៅហ្នឹងទាំងអស់ រួមគ្នាតាំងពី៧៩ គេបូកតាំងពីឆ្នាំ ពីសីហនុ មកដល់ ៧៩ និយាយរួមទៅអ៊ីចឹង។

**ស៖** សូមអរគុណ។ មុននេះលោកស្រីបាននិយាយថា ចំពោះការរៀបអាពាហ៍ពិពាហ៍ជនជាតិចាម ត្រូវតែរៀបការជាមួយចាមគ្នាឯង។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកស្រីធ្លាប់ចូលរួមក្នុងការរៀបអាពាហ៍ពិពាហ៍របស់ជនជាតិចាមទេ នៅពេលដែលលោកស្រីទៅដល់ស្រុកកំពង់សៀមនោះ?

**ឆ៖** មានៗរៀប ប៉ុន្តែវាអត់មានហេតុការណ៍អ្វីទេ។

[១៥:៥៥:១៧]

**ស៖** លោកស្រីថាអត់មានហេតុការណ៍អ្វីទេហ្នឹង លោកស្រីចង់មានន័យថាម៉េច? ពាក្យហ្នឹងថា “មិនមានហេតុការណ៍អ្វីទេ” លោកស្រីចង់មានន័យថាម៉េចដែរ?

**ឆ៖** មានន័យថា រៀបទៅវាត្រូវតម្រូវគ្នាជាគ្រួសាររបស់វា រួចទៅវាអត់មានឈ្លោះប្រកែកគ្នាវាអត់មានបាក់បែកគ្នាអី វាប្រឹងប្រែងរកស៊ីធ្វើការតាមសង្គម។

**ស៖** លោកស្រីទើបតែនិយាយថា លោកស្រីបានចូលរួមក្នុងការរៀបការរបស់ជនជាតិចាម។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលគេរៀបការជនជាតិចាមហ្នឹង គេរៀបការក្នុងពេលតែមួយជាមួយខ្មែរ ឬក៏គេរៀបការដាក់គូខ្មែរផ្សេង ចាមផ្សេងនៅដាច់ដោយឡែកពីគ្នា?

**ឆ៖** អង្គាល់ណារៀបទៅដាក់ខ្មែរមួយជួរទៅ ដាក់ជនជាតិចាមមួយជួរទៅ រៀបថ្ងៃជាមួយគ្នា។

**ស៖** សូមអរគុណ។ តើលោកស្រីចាំថ្ងៃខែឆ្នាំនៃការរៀបការហ្នឹងទេ? ពេលការហ្នឹងលោកស្រីក្លាយជាអនុឃុំហើយ ឬក៏មុនពេលនោះ?

**ឆ៖** និយាយរួមទៅ ខ្ញុំអនុឃុំផង ប្រធានកងចល័តផង វាពីរផ្នែក នីរសារផង។ កាលណាគាត់ហៅប្រើទៅ ទៅណាក៏បានដែរ ផ្នែកទាំងបី។

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយបញ្ជាក់។ ខ្ញុំយល់ថា ដំបូងលោកស្រីជាប្រធានកង

ចល័ត ក្រោយមកទៀតគេបញ្ជូនលោកស្រីឲ្យទៅធ្វើជាអនុប្រធានភូមិ។ អ៊ីចឹងខ្ញុំចង់ដឹងថា ពេលដែលលោកស្រីកាន់មុខងារហ្នឹង កាន់ម្តងទាំងពីរហ្នឹង ឬកាន់មុខងារមុនដំបូងធ្វើប្រធានកង បន្ទាប់មកទើបក្លាយជាអនុឃុំទេ?

**ឆ៖** មុនដំបូងកងចល័ត ដល់តែពេលខ្ញុំ គាត់ឲ្យទៅធ្វើអនុឃុំ ខ្ញុំទៅធ្វើអនុឃុំទៀត ប៉ុន្តែការងារកងចល័តនៅដដែល។ ដល់តែពេលគាត់ ខ្ញុំទៅធ្វើអនុឃុំទៀត ខ្ញុំនៅសិទ្ធិជានីរសាររបស់គាត់ដដែល គាត់នៅប្រើបានទាំងអស់។

[១៥:៥៨:៤០]

**ស៖** សូមអរគុណ ខ្ញុំយល់ច្បាស់ហើយ។ លោកស្រីថាជនជាតិចាមរស់នៅជាមួយជនជាតិខ្មែរនៅតាមភូមិផ្សេងៗនៅក្នុងស្រុកកំពង់សៀម។ ចុះក្រោយពីធ្វើបញ្ជីឈ្មោះហើយនោះ តើលោកស្រីមានឃើញ មានភាពខុសគ្នាអ្វីទេ ដែលកើតឡើងចំពោះជនជាតិចាមនោះ?

**ឆ៖** គឺតាមដានទៅគឺធម្មតា។ ធ្វើការងារជាមួយគ្នារាល់ថ្ងៃ ប៉ុន្តែគ្រាន់តែខ្ញុំឆ្ងល់តែបាត់មនុស្សជាប់តែប៉ុណ្ណឹងទេ មនុស្សណាល្អៗអត់បាត់ទេ។

**ស៖** លោកស្រីឆ្លើយថា ក្រោយពីធ្វើបញ្ជីរួច លោកស្រីកត់សម្គាល់ឃើញថាមានមនុស្សបាត់ខ្លួន។ ចុះជនជាតិចាមផ្ទាល់តែម្តង លោកស្រីមានបានឃើញថាមានបាត់ខ្លួនទេ?

**ឆ៖** បាត់តែអ្នកដែលបាត់ ដែលអ្នកនៅៗសុខសប្បាយ។ អ្នកដែលបាត់ គឺបាត់។

**ស៖** លោកស្រី -- លោកប្រធាន ប្រហែលជាសំណួរចុងក្រោយមុនពេលឈប់សម្រាក។ លោកស្រីបានបញ្ជាក់ថានៅក្នុងបញ្ជីឈ្មោះនោះ មានជនជាតិវៀតណាមផងដែរ។ អ៊ីចឹងខ្ញុំចង់ដឹងថា តើមានជនជាតិដើមវៀតណាមហ្នឹតតែម្តង មករស់នៅក្នុងភូមិហ្នឹងទេ ឬក៏វៀតណាមហ្នឹងជាវៀតណាមកូនកាត់ទេ?

**ឆ៖** វៀតណាមហ្នឹង វាមកនៅ ដូចថាមកនៅស្នាក់អាស្រ័យមករកត្រី មករកអីនៅតាមមាត់ទន្លេទេ។ វាគ្មានដីនៅ វានៅតែនេះទៅ វាសុំស្នាក់អាស្រ័យប្រជាជនយើងខ្មែរហ្នឹង ខ្លះណាក៏វាមានលុយទិញដីទៅ វាដាក់ឈ្មោះថាជនជាតិ។ វាអត់មាន ដូចថាបញ្ជី មានដី មានផ្ទះ មានអី ហ្នឹងប្រធានភូមិគេស្រង់ហ្នឹងគេដាក់ថាជនជាតិហើយ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំគិតថាដល់ម៉ោងឈប់សម្រាកហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ហើយបានស្តាប់លោកស្រី ក្នុងការតាំងសំណួរ លោកស្រីប្រើពាក្យថា ការតាំងសំណួរនៅសាក្សីនេះ នៅរសៀលនេះ ហើយនឹងបន្តទៅព្រឹកថ្ងៃចន្ទដើមសប្តាហ៍ក្រោយទៀត។ យើងចង់ដឹងថា មានហេតុផលម៉េចទៅ ព្រោះអង្គជំនុំជម្រះបានផ្តល់វេទិកាជូនទៅភាគីទាំងពីរ។ បញ្ជាក់ហើយថាភាគីទាំងពីរនេះមានពេលវេលាពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរសាក្សីរូបនេះ។ ពីរវគ្គ បានន័យថាមួយព្រឹក ឬក៏មួយរសៀល។ ហើយមិញនេះ ទំនងជាមានបំណងចង់តាំងសំណួរសាក្សីរូបនេះបន្តទៅថ្ងៃចន្ទទៀត ដើមសប្តាហ៍ក្រោយទៀត។ សំណួរថាវាមានហេតុផលយ៉ាងម៉េចទៅ ហើយបើត្រូវការសុំនោះ សុំប៉ុន្មានដើម្បីអង្គជំនុំជម្រះសម្រេចលើបញ្ហានេះឲ្យបានច្បាស់លាស់ជាមុនសិន មុននឹងសម្រាក។

[១៦:០៣:០៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន គឺយើងបានចាប់ផ្តើម២០នាទី យឺតពេលហើយ។ អ៊ីចឹងខ្ញុំគិតថា គួរតែយើងទទួលបានពេលវេលា២០នាទី ដែលលោកប្រធានបានប្រើសម្រាប់សួរសាក្សី។ អ៊ីចឹងខ្ញុំគិតថា ប្រហែលជាខ្ញុំត្រូវការពេល១០នាទីជាងទៀត ដើម្បីសួរសាក្សី។ នេះជាអ្វីដែលយើងបានគណនាជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា។

**ប្រធានអង្គជំនុំ៖**

ទី១ យើងបានជម្រាបហើយ អំពីបញ្ហានោះ។ ទី២ បញ្ហានៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានបញ្ជាក់ នៅគ្រប់ពេលគឺតែងតែមានការប្រើប្រាស់នូវពេលវេលាមួយចំនួនសម្រាប់តាំងសំណួរបឋមរបស់ប្រធានអង្គជំនុំជម្រះ ហើយនិងអំមិញនេះមានការផ្សព្វផ្សាយនូវសេចក្តីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះបានជួសជុលនៅពេលសម្រាក អង្គជំនុំជម្រះប្រកាសសម្រាក់ពីម៉ោងនេះទៅម៉ោងនេះ មានន័យថាអត់បានប្រកាសថារយៈពេលប៉ុន្មានទេ។ តាមធម្មតា គឺសម្រាក២០នាទី ប៉ុន្តែយើងសម្រាកជាក់ស្តែងគឺតែ១៥នាទីទេ បំណងជួសជុលប្រាំនាទីបន្ថែម។ ហើយការដោះស្រាយជាមួយនឹងខាងសហ -- តំណាងសហព្រះរាជអាជ្ញាគួរតែនិយាយគ្នាឲ្យបានច្បាស់លាស់អំពីភាពសំខាន់ចាំបាច់នៅក្នុងការបែងចែកពេលវេលាគ្នា។ ឥឡូវយើងសម្រេចអនុញ្ញាតថាឲ្យ១០នាទី ប៉ុន្តែឥឡូវនេះមិនអាចសួរថ្ងៃនេះបានទេ អាចបន្តសួរនៅថ្ងៃចន្ទក្រោយ។ ប៉ុន្តែលើកក្រោយមិនអាចធ្វើដូច្នេះបានទេ ត្រូវពិភាក្សាចែកពេលវេលារវាងខ្លួនជាមួយនឹងសហ តំណាងសហព្រះរាជអាជ្ញាឲ្យបានច្បាស់លាស់ លើពេលវេលាក្នុងការបែងចែកក្នុងការ

តាំងសំណួរនេះ។ មិនមែនម្នាក់ប្រើពេលវេលាយ៉ាងច្រើនលើសលប់ ហើយសល់បន្តិចបន្តួចមកថែម សុំថែមនោះទេ។

[១៦:០៥:១១]

បាទ សវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃច័ន្ទ ទី១៨ ខែមករា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃចន្ទ ដើមសប្ដាហ៍ក្រោយនេះអង្គជំនុំជម្រះនឹងធ្វើសវនាការ ស្ដាប់សក្ខីកម្មសាក្សី យូ វ៉ាន់ បន្តបញ្ចប់ ហើយផ្ដើមស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម [2-TCW-938] សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកស្រី យូ វ៉ាន់ ដំណើរការសវនាការស្ដាប់សក្ខីកម្មរបស់លោកស្រីក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ។ អង្គជំនុំជម្រះកោះអញ្ជើញលោកស្រីឲ្យមកផ្ដល់សក្ខីកម្មនៅថ្ងៃចន្ទទី១៨ ខែមករា ឆ្នាំ២០១៦ ដើមសប្ដាហ៍ក្រោយទៀតដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សីនិងអ្នកជំនាញក្នុងការជូនលោកស្រី យូ វ៉ាន់ ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅ និងសូមឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការនៅថ្ងៃចន្ទ ទី១៨ ខែមករា ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី។ អង្គជំនុំជម្រះក៏សូមអញ្ជើញលោកមកចូលរួម ប្រឹក្សាសាក្សីរូបនេះ ដែលនឹងបន្តធ្វើនៅថ្ងៃចន្ទ ទី១៨ ខែមករា ឆ្នាំ២០១៦ ដើមសប្ដាហ៍ក្រោយនេះ។

បង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបលោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវ-នាការនៅថ្ងៃចន្ទ ទី១៨ ខែមករា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*